សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អគ្រានុក្កូលដ្ឋាន

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **យុំ សំណាង**
**ម៉ៅ ផាវីន**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក វុឌ្ឍី**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៥

ឆ្នាំចូលសិក្សា ២០១១
ឆ្នាំសរសេរសារណា ២០១៥

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន**

**១.១ ៖ សៀវភៅអត្រានុកូលដ្ឋាន** ........ ៣

១.១.១ ៖ ប្រភេទនៃសៀវភៅអត្រានុកូលដ្ឋាន ........ ៣

១.១.២ ៖ ការប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋាន ........ ៣

១.១.២.១ ៖ ការចុះបញ្ជីលេខរៀងនៃសៀវភៅ ........ ៤

១.១.២.២ ៖ កំហុសកើតមានក្នុងពេលសរសេរបញ្ជី ........ ៥

១.១.២.៣ ៖ ការសរសេរបិទសៀវភៅអត្រានុកូលដ្ឋាន ........ ៥

**១.២ ៖ សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន** ........ ៦

**១.៣. ៖ សារៈប្រយោជន៍នៃអត្រានុកូលដ្ឋាន** ........ ៦

១.៣.១ ៖ ចំពោះសង្គមជាតិ ........ ៧

១.៣.២ ៖ ចំពោះពលរដ្ឋ ........ ៧

**១.៤ ៖ បំរាម និងការទទួលត្រូវចំពោះមុខច្បាប់ស្តីពីអត្រានុកូលដ្ឋាន** ........ ៨

១.៤.១ ៖ បំរាម ........ ៨

១.៤.២ ៖ ការទទួលខុសត្រូវ.. ........ ៩

**ជំពូកទី ២**

**ភារកិច្ចរបស់សមត្ថកិច្ចការងារអត្រានុកូលដ្ឋាន**

**២.១ ៖ ថ្នាក់ក្រសួង** ........ ១០

**២.២ ៖ ថ្នាក់រាជធានីខេត្ត** ........ ១០

**២.៣ ៖ ថ្នាក់ក្រុង ស្រុក ខណ្ឌ** ........ ១១

**២.៤ ៖ ថ្នាក់ឃុំ សង្កាត់** ........ ១២

**២.៥ ៖ ថ្នាក់ភូមិ** ........ ១៣

**ជំពូកទី ៣**

**ការចុះសៀវភៅ និង សំបុត្រអត្រានុកូលដ្ឋាន**

**៣.១ ៖ អត្រានុកូលដ្ឋានកំណើត** ........ ១៥

៣.១.១ ៖ សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត ........ ១៥

៣.១.២ ៖ ការចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើត ........ ១៥

៣.១.២.១ ៖ លិខិតស្នាមនានាដែលទាក់ទងនឹងកំណើត ........ ១៥

៣.១.២.២ ៖ ការសរសេរចុះបញ្ជីកំណើត ........ ១៦

ក ៖ ការចុះបញ្ជីកំណើតសម្រាប់ទារកដែលកើតពីឪពុកម្តាយជាពលរដ្ឋខ្មែរ.. ............ ១៧
ខ ៖ ការចុះបញ្ជីកំណើតសម្រាប់ទារកជនបរទេស និងអន្តោប្រវេសរស់នៅស្របច្បាប់ក្នុងកម្ពុជា........ ១៨
៣.១.២.៣ ៖ ការសរសេរសំបុត្រច្បាប់ដើមមួយសន្លឹក ........ ១៩
៣.១.៣ ៖ ការសរសេរចុះអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត........ ២០
៣.១.៣.១ ៖ លិខិតស្នាមនានាដែលទាក់ទងនឹងបញ្ជាក់កំណើត........ ២០
៣.១.៣.២ ៖ ការចុះបញ្ជីបញ្ជាក់កំណើត........ ២១
៣.១.៣.៣ ៖ ការសរសេរសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក........ ២១
៣.១.៤ ៖ សេចក្តីចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត ........ ២១
៣.១.៤.១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងបញ្ជាក់កំណើត........ ២២
៣.១.៤.២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើត.. ........ ២២
៣.២ ៖ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍........ ២៣
៣.២.១ ៖ សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍........ ២៣
៣.២.២ ៖ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹង និងការបិទប្រកាស........ ២៣
៣.២.៣ ៖ ការចុះសៀវភៅអត្រានុកូលអាពហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ ........ ២៤
៣.២.៣.១ ៖ ការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ.... ២៤
៣.២.៣.២ ៖ ការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស .. ២៥
៣.២.៣.៣ ៖ ការសរសេរសំបុត្រច្បាប់ដើមមួយសន្លឹក........ ២៦
៣.២.៤ ៖ សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់អាពាហ៍ពិពាហ៍........ ២៦
៣.២.៤.១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់អាពាហ៍ពិពាហ៍ ២៧
៣.២.៤.២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង បញ្ជាក់អាពាហ៍ពិពាហ៍.. ២៧
**៣.៣ ៖ អត្រានុកូលដ្ឋានមរណភាព** ........ ២៨
៣.៣.១ ៖ សៀវភៅ និងក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព........ ២៨
៣.៣.២ ៖ ការសរសេរចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និងសំបុត្រមរណភាព........ ២៨
៣.៣.២.១ ៖ លិខិតស្នាមនានាពាក់ព័ន្ធនឹងសព ........ ២៨
ក ៖ករណីការចុះអត្រានុកូលដ្ឋានមរណភាពក្នុងរយៈពេលកំណត់១៥ថ្ងៃ........ ២៩
ខ ៖ ករណីការចុះអត្រានុកូលដ្ឋានមរណភាពហួសរយៈពេលកំណត់១៥ថ្ងៃ ក្នុងឆ្នាំ ..... ២៩
គ ៖ ករណីការចុះអត្រានុកូលដ្ឋានមរណភាពទុកឲ្យហួសឆ្នាំ ........ ៣០
៣.៣.២.២ ៖ ការសរសេរលិខិតអនុញ្ញាតអោយធ្វើបុណ្យបូជាសព ឬបញ្ចុះសព........ ៣០
៣.៣.២.៣ ៖ ការចុះបញ្ជីមរណភាព ........ ៣១
៣.៣.២.៤ ៖ ការសរសេរសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក........ ៣២
៣.៣.៣ ៖ សេចក្តីចម្លង ឬសម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព........ ៣៣

៣.៣.៣.១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងបញ្ជាក់មរណភាព ...... ៣៣
៣.៣.៣.២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រមរណភាព និងបញ្ជាក់មរណភាព .............. ៣៤
**សេចក្តីសន្និដ្ឋាន ៖** ........................................ ៣៥
**អនុសាសន៍** ........................................ ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ជាការពិតណាស់ប្រទេសកម្ពុជា ជាប្រទេសមួយដែលទទួលរងនូវសង្គ្រាមដ៏រាំរ៉ៃ និងបានអូសបន្លាយជាច្រើនទសវត្ស បញ្ហាសង្គ្រាមនេះបានធ្វើឲ្យកម្ពុជាបាត់បង់ នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធនធានមនុស្ស និង លិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ទាំងនេះហើយដែលបង្កឲ្យប្រទេសកម្ពុជាបានជួបផលលំបាកជាច្រើនដូចជា កុមារកំព្រា ស្ត្រីមេម៉ាយ ជនពិការ ព្រាត់ប្រាស់វិនាសគ្រួសារ ជាពិសេសនោះធ្វើឲ្យបាត់បង់នូវឯកសារសម្គាល់ខ្លួន នាំឲ្យមានការភ័ន្តច្រឡំ និងបង្កឲ្យមានភាពរញ៉េរញ៉ៃនៅក្នុងសង្គម ។ ឆ្លើយតបទៅនិងបញ្ហាខាងលើនេះ រាជរដ្ឋាភិបាលបានបង្កើតឲ្យមានអនុក្រឹត្យមួយឡើងនៅក្នុងឆ្នាំ ២០០០ ស្តីពីអត្រានុកូលដ្ឋាន ។

នៅក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននេះ មានគោលបំណងសម្រាប់គ្រប់គ្រង និង កត់ត្រាភាពស៊ីវិលនៃប្រជាពលរដ្ឋខ្មែរ និងបរទេសដែលរស់នៅស្របច្បាប់ នៅក្នុងដែនសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ហើយតាមរយៈអនុក្រឹត្យនេះផងដែរឃើញថាមានសំបុត្រអត្រានុកូលដ្ឋានចំនួន៣ សំខាន់ៗដូចជា **សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព** ។

ដើម្បីឲ្យយល់កាន់តែច្បាស់ទាក់ទងនឹងបញ្ហាអត្រានុកូលដ្ឋាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំទាំងពីរនាក់ក៏បានសម្រេចចិត្តធ្វើការស្រាវជ្រាវនូវសារណាមួយ ក្រោមប្រធានបទ » **អត្រានុកូលដ្ឋាន** « ហើយតាមរយៈសារណានេះ យើងឃើញថា ពិតជាបានធ្វើឲ្យប្រជាពលរដ្ឋបានស្គាល់ពីសារសំខាន់ និង តម្លៃនៃសំបុត្រអត្រានុកូលដ្ឋាន មួយវិញទៀតក៏បានចូលរួមចំណែកក្នុងការជួយសម្រួលការអនុវត្តការងាររដល់មន្ត្រីអត្រានុកូលដ្ឋាន ក្នុងការអភិវឌ្ឍសង្គមដើម្បីឈានទៅរកនីតិរដ្ឋ មិនតែប៉ុណ្ណោះ សារណានេះក៏ជាឯកសារមួយសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗទៀត ដើម្បីសិក្សាស្វែងយល់បន្ថែមទាក់ទងនឹងការងារអត្រានុកូលដ្ឋាន ។

តើអត្រានុកូលដ្ឋានបានផ្តល់នូវសារសំខាន់យ៉ាងដូចម្តេចខ្លះ ចំពោះប្រជាពលរដ្ឋខ្មែរ និង សង្គមជាតិ ? ហើយពាក្យថា អត្រានុកូលដ្ឋានមានអត្ថន័យយ៉ាងដូចម្តេច ? ហើយតើនីតិវិធីនៃការចុះបញ្ជីសៀវភៅ និង លិខិតអត្រានុកូលដ្ឋានប្រព្រឹត្តទៅយ៉ាងដូចម្តេចឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ ? យើងខ្ញុំនឹងធ្វើការបកស្រាយនៅក្នុងជំពូកនីមួយៗនៃសារណានេះ ។

ងារគោលបំណងនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំចង់សិក្សាស្វែងយល់បន្ថែមទាក់ទងទៅនឹងការមួយគ្រងអត្រានុកូលដ្ឋាន យ៉ាងណាមិញប្រទេសដែលមានការរីកចំរើនចាំបាច់ទាមទារឲ្យមានការគ្រប់ស់លាស់ ។ ម្យ៉ាងវិញទៀត អត្រាដែលមានភាពច្បានុកូលដ្ឋានជាផ្នែកមួយរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និង ភាពរីកចំរើនរបស់ប្រទេសជាតិ ។

ដែនកំណត់ និងវិសាលភាពនៅក្នុងការស្រាវជ្រាវនេះ នឹងសិក្សាផ្តោតសំខាន់ទៅលើ អត្រានុកូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និង អត្រានុកូលដ្ឋាននៅឯក្រៅប្រទេស សម្រាប់ពលរដ្ឋខ្មែរនឹង ពលរដ្ឋខ្មែររស់នៅបរទេស និង សម្រាប់ពលរដ្ឋខ្មែរនឹងពលរដ្ឋបរទេសរស់នៅបរទេសចាប់ពី ឆ្នាំ ២០០២ រហូតមកទល់នឹងថ្ងៃសរសេរសារណានេះតែប៉ុណ្ណោះ ។

ដើម្បីឆ្លុះបញ្ចាំងពីខ្លឹមសារ ក៏ដូចជាការឆ្លើយតបទៅនិងបញ្ហាដែលបានរៀបរាប់ខាងលើ សារណានេះត្រូវបានធ្វើការបែងចែកជាបីជំពូក ។ ជំពូកទី១ គឺបង្ហាញអំពី « **សញ្ញាណទូទៅនៃអត្រានុកូល**

**ដ្ឋាន »** ជំពូកទី២ គឺបង្ហាញអំពី « **ភារកិច្ចរបស់សមត្ថកិច្ចការងារអគ្រានុកូលដ្ឋាន »** ជំពូកទី៣ គឺបង្ហាញអំពី« **ការចុះសៀវភៅ និង សំបុត្រអគ្រានុកូលដ្ឋាន »** ។

# ជំពូកទី ១

# សញ្ញាណទូទៅនៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែងដែលជននោះមាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ ព្រមទាំងបង្កើតឲ្យជននោះមានសិទ្ធិ និងករណីកិច្ច ។

សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃប្រជាពលរដ្ឋខ្មែរ និងបរទេសដែលរស់នៅស្របច្បាប់ ក្នុងដែលសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា ។ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្រមរណភាព ។[1]

## ១.១ ៖ សៀវភៅអត្រានុកូលដ្ឋាន

នៅក្នុងឃុំ ឬ សង្កាត់នីមួយៗត្រូវមានសៀវភៅអត្រានុកូលដ្ឋាន សម្រាប់កត់ត្រាអំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព បញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ បញ្ជាក់មរណភាព ។ សៀវភៅនេះធ្វើឡើងជា ០២ច្បាប់ ( សៀវភៅភ្លោះ ) ដូចគ្នាតាមប្រភេទនីមួយៗ តាមគំរូដែលកំណត់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។[2]

### ១.១.១ ៖ ប្រភេទសៀវភៅអត្រានុកូលដ្ឋាន

**ប្រភេទសៀវភៅអត្រានុកូលដ្ឋានរួមមាន៖**

- សៀវភៅអត្រានុកូលដ្ឋានកំណើត
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ ( ដែលបានអនុវត្តអំឡុងឆ្នាំ២០០២-២០០៧ )
- សៀវភៅអត្រានុកូលដ្ឋានមរណភាព
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ( ដែលបានអនុវត្តក្នុងអំឡុងឆ្នាំ ២០០២-២០០៧ )
- សៀវភៅអត្រានុកូលដ្ឋានកំណើតជនបរទេស និង ជនអន្តោប្រវេស្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ជនបរទេស និង ជនអន្តោប្រវេស្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានមរណភាពជនបរទេស និង ជនអន្តោប្រវេស្តស្របច្បាប់ ។

### ១.១.២ ៖ ការប្រើប្រាស់សៀវភៅអត្រានុកូលដ្ឋាន

[1] មាត្រា២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជា ឆ្នាំ ២០០០
[2] មាត្រា១២ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជា ឆ្នាំ ២០០០

សៀវភៅទាំងនេះ សាលាក្រុង ស្រុក ខណ្ឌ ត្រូវបញ្ជូនទៅឲ្យឃុំ ឬ សង្កាត់ក្នុងអំឡុងខែធ្នូនៃឆ្នាំនីមួយៗ ។ ក្នុងឆ្នាំនៅពេលដែលប្រើប្រាស់សៀវភៅជិតអស់ ឃុំ ឬ សង្កាត់ ត្រូវទៅស្នើរសុំពីសាលាក្រុង ស្រុក ខណ្ឌ ដើម្បីត្រៀមទុកអនុវត្តបន្ត ។ សៀវភៅអត្រានុកូលដ្ឋានក្នុងឆ្នាំនីមួយៗ ត្រូវបើកអោយប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែ មករា ហើយត្រូវបានបញ្ឈប់នៅថ្ងៃទី៣១ ខែ ធ្នូរៀងរាល់ឆ្នាំ ។ នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនសៀវភៅអត្រានុកូលដ្ឋាននៃប្រភេទនីមួយៗ ដែលបានកត់ត្រារួច

- ០១ច្បាប់ ទៅសាលាក្រុង ស្រុក ខណ្ឌសាមីដើម្បីត្រួតពិនិត្យ និង តម្កល់ទុកនៅទីនោះ
- ០១ច្បាប់ទៀត ទៅតម្កល់ទុកនៅក្រសួងមហាផ្ទៃ ។

សៀវភៅអត្រានុកូលដ្ឋានដែលប្រើប្រាស់ នៅស្ថានទូត ឬ អគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស ត្រូវបញ្ជូនតាមរយៈក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៅខែ មករា ឆ្នាំបន្ទាប់មកតម្កល់ទុក ០១ច្បាប់នៅក្រសួងមហាផ្ទៃ និង ០១ច្បាប់ទៀតនៅក្រសួងយុត្តិធម៌ ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំទុកដាក់សៀវភៅអត្រានុកូលដ្ឋាន និង សំណុំឯកសារដែលពាក់ព័ន្ធ នឹងការងារអត្រានុកូលដ្ឋានឲ្យបានគង់វង្ស ។ មន្ត្រីអត្រានុកូលដ្ឋាន និង មន្ត្រីរក្សាសៀវភៅអត្រានុ-កូលដ្ឋាន ត្រូវរក្សាការសម្ងាត់របស់បុគ្គលម្នាក់ៗ គឺមិនត្រូវនិយាយឲ្យអ្នកផ្សេងដឹងឮ ឬ អនុញ្ញតអោយអ្នកដែលគ្មានភារកិច្ចបើកមើលឡើយ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវរៀបចំទុកដាក់សៀវភៅអត្រានុកូលដ្ឋានដែលឃុំ សង្កាត់ផ្ញើរមក ដោយតម្កល់ទុកឲ្យបានគង់វង្សតាមប្រភេទនីមួយៗ តាមឃុំ ឬ សង្កាត់ តាមលំដាប់ឆ្នាំ និងតាមលេខរៀងសៀវភៅឲ្យបានត្រឹមត្រូវ ។ ក្នុងករណីបាត់បង់ ឬ ខូចខាតសៀវភៅអត្រានុកូលដ្ឋានមន្ត្រីអត្រានុកូលដ្ឋាន និង មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ហេតុត្រឹមត្រូវស្តីពីការបាត់បង់ ឬ ការខូចខាតនេះផ្ញើរទៅក្រសួងមហាផ្ទៃជាបន្ទាន់ ដោយបញ្ជូនតាមរយៈសាលាក្រុង ស្រុក ខណ្ឌ រាជធានី ខេត្តសាមី ។ ក្រោយពីមានសេចក្តីណែនាំពីអន្តរក្រសួងទើបធ្វើការចម្លង ឬ សម្រង់ចេញពីសំបុត្រអត្រានុកូលដ្ឋាន ឬ សំបុត្របញ្ជាក់អត្រានុកូលដ្ឋាន ដែលសាមីខ្លួនអ្នកសុំ រួចប្រគល់ឲ្យយកទៅប្រើប្រាស់វិញ ។[3]

### ១.១.២.១ ៖ ការចុះលេខរៀងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន

លេខរៀងបញ្ជីអត្រានុកូលដ្ឋានត្រូវចុះតាមប្រភេទនៃសៀវភៅអត្រានុកូលដ្ឋាននីមួយៗ ដោយចាប់ផ្តើមពីលេខ ០១ ក្នុងបញ្ជីដំបូងសម្រាប់អ្នកមកចុះសៀវភៅអត្រានុកូលដ្ឋានតាមប្រភេទនីមួយៗមុនគេ រួចបន្តចុះលេខ ០២ បន្តបន្ទាប់សម្រាប់អ្នកចុះបន្ទាប់ទៀតរហូតដល់បញ្ជីចុងក្រោយ ។ ក្នុងករណីចុះបញ្ជីក្នុងសៀវភៅភ្លោះទីមួយ ហើយមិនទាន់ដាច់ឆ្នាំ ( ក្នុងឆ្នាំដដែល ) ត្រូវចុះលេខរៀងបញ្ជីអត្រានុកូល

[3] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

ដ្ឋានសៀវភៅអត្រានុកូលដ្ឋានភ្លោះទីពីរ បន្តពីលេខរៀងបញ្ជីអត្រានុកូលដ្ឋានចុងក្រោយនៃសៀវភៅអត្រានុកូលដ្ឋានភ្លោះទីមួយ ។

ឧទាហរណ៍ ៖ សៀវភៅលេខ ០១/២០១៥ លេខបញ្ជីត្រូវចាប់ផ្តើមពីលេខ០១ ហើយត្រូវបញ្ចប់លេខ៩០ ដូចច្នេះលេខបញ្ជីនៃសៀវភៅវអត្រានុកូលដ្ឋានលេខ ០២/២០១៥ ត្រូវចាប់ផ្តើមពីលេខ ៩១ ក្នុងបញ្ជីដំបូង រួចចុះលេខ ៩២ជាបន្តបន្ទាប់ ។ លេខរៀងបញ្ជីអត្រានុកូលដ្ឋាន ត្រូវចុះពេលចាប់ផ្តើមសរសេរចូលបញ្ជីអត្រានុកូលដ្ឋាន ហើយមន្ត្រីអត្រានុកូលដ្ឋានមិនត្រូវចុះលេខរៀងទុកជាមុន និងរំលងនោះទេ ។ នៅឆ្នាំថ្មីលេខរៀងបញ្ជីអត្រានុកូលដ្ឋាន ត្រូវចាប់ផ្តើមពីលេខ០១ឡើងវិញ ។

### ១.១.២.២ ៖ កំហុសកើតមានក្នុងពេលសរសេរបញ្ជីអត្រានុកូលដ្ឋាន

បញ្ជីអត្រានុកូលដ្ឋានមិនត្រូវឲ្យមានកោស ឆូត លុប សរសេរជ្រៀតថែមឡើយ ប្រសិនបើមានការសរសេរខុសចំពោះបញ្ជីអត្រានុកូលដ្ឋានណាមួយត្រូវអនុវត្តដូចខាងក្រោម ៖

កំហុសអាចកែតម្រូវបាន គឺការសរសេរខុសអក្ខរាវិរុទ្ធ និង លេខបន្តិចបន្តួច ត្រូវឆូតពាក្យដែលខុសទាំងអស់នោះដោយទឹកប៊ិចពណ៌ក្រហម ដោយទុកពាក្យខុសទាំងនោះនៅអាចមើលបាន បន្ទាប់មកសរសេរពាក្យត្រឹមត្រូវនៅទន្ទឹម ឬ បន្ទាប់ពីលើពាក្យខុសទាំងនោះដោយទឹកប៊ិចពណ៌ខៀវ បន្ទាប់មកទៀតត្រូវសរសេរដោយទឹកប៊ិចពណ៌ក្រហម នៅលើរឹមទំព័រខាងឆ្វេងថា**យល់ « ព្រមលុបពាក្យ......... និងយល់ព្រមសរសេរពាក្យ.........ជំនួសទៅវិញ** » រួចមន្ត្រីអត្រានុកូលដ្ឋានចុះហត្ថលេខាអ្នករាយការណ៍ ឬ សាមីខ្លួនផ្តិតមេដៃស្តាំ ។

កំហុសមិនអាចកែតម្រូវបានគឺ កំហុសច្រើនពេក សរសេរ ឬ បំពេញខុសខ្ទង់ ក្នុងករណីបញ្ជីអត្រានុកូលដ្ឋានណាមួយដែលបានបំពេញខុស ឬ សរសេរខុស ហើយមិនអាចកែតម្រូវបាន ត្រូវទុកជាមោឃៈដោយសរសេពាក្យ « **ទុកជាមោឃៈ** » ជាអក្សរធំៗដោយទឹកប៊ិចពណ៌ក្រហមនៅចំកណ្តាលបញ្ជីដែលទុកជាមោឃៈនោះ បន្ទាប់មកសរសេរចុះថ្ងៃ ខែ ឆ្នាំ និងចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងបោះត្រា ហើយរក្សាទុកជាឯកសារ ។ ចំពោះបញ្ជីអត្រានុកូលដ្ឋានដែលទុកជាមោឃៈ មិនអនុញ្ញាតឲ្យហែកចោល ឬ បោះបង់ចោលឡើយ បើសិនមានបញ្ជីអត្រានុកូលដ្ឋានណាមួយទុកជាមោឃៈ នោះបញ្ជីអត្រានុកូលដ្ឋាន នៃសៀវភៅភ្លោះមួយក្បាលទៀត ក៏ត្រូវទុកជាមោឃៈដែរ ហើយបញ្ជីអត្រានុកូលដ្ឋានបន្ទាប់ត្រូវយកលេខរៀងដដែល ។

### ១.១.២.៣ ៖ ការសរសេរបិទសៀវភៅអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរបិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលសៀវភៅប្រើប្រាស់បញ្ជី និង នៅដំណាច់ឆ្នាំ ។ ការសរសេរបិទសៀវភៅត្រូវសរសេរនៅលើបញ្ជីអត្រានុកូលដ្ឋាន ក្នុងករណី

សៀវភៅប្រើប្រាស់មិនទាន់អស់ ត្រូវសរសេរបន្ទាប់ពីបញ្ជីអត្រានុកូលដ្ឋានដែលបានសរសេរចុងក្រោយ និង ក្នុងករណីសៀវភៅប្រើប្រាស់អស់បញ្ជី ត្រូវសរសេរនៅទំព័រចុងក្រោយគេបំផុត ។

**ឧទាហរណ៍** ៖ របាយការណ៍ដែលមន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរនៅលើបញ្ជីគឺ

ផ្អែកតាមផែនការនៃយុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័តទូទាំងប្រទេស សៀវភៅអត្រានុកូលដ្ឋានកំណើត ០២៣៤ /២០១៥ ដែលមានលេខរៀងបញ្ជីបានកំណត់ពីលេខ ៥៧៨៩ ( ប្រាំពាន់ប្រាំពីររយប៉ែតសិបប្រាំបួន ) ដល់លេខ៦៣៥៦ ( ប្រាំមួយពាន់បីរយសែសិបប្រាំមួយ ) ។ ជាក់ស្តែងសៀវភៅនេះអនុវត្តពីលេខរៀង ៥៧៨៩ ( ប្រាំពាន់ប្រាំពីររយប៉ែតសិបប្រាំបួន ) ដល់លេខ ៦៣៥៦ ( ប្រាំមួយពាន់បីរយសែសិបប្រាំមួយ ) ។

## ១.២ ៖ សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន

សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន មិនត្រូវចាត់ទុកជាសៀវភៅអត្រានុកូលដ្ឋាននោះទេ ។ សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋាន រួមមាន ៖

- សៀវភៅចម្លងសំបុត្រកំណើត និង ចម្លងសំបុត្របញ្ជាក់កំណើត
- សៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង ចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍
- សៀវភៅចម្លងសំបុត្រមរណភាព និង ចម្លងសំបុត្របញ្ជាក់មរណភាព

សៀវភៅចម្លងអត្រានុកូលដ្ឋានគ្រប់ប្រភេទត្រូវ ៖

- អនុវត្តតែមួយក្បាល ( មិនធ្វើពីរក្បាលជាភ្លោះ ) ដូចសៀវភៅអត្រានុកូលដ្ឋានឡើយ ។
- ចុះលេខរៀងតាមប្រភេទនីមួយៗ និង តាមឆ្នាំនីមួយៗ ដោយចាប់ផ្តើមពីលេខ០១ ពេលអនុវត្តដំបូងគេបំផុត ( នៅដើមឆ្នាំ ) ហើយចុះលេខរៀងបន្តបន្ទាប់ រហូតដល់នៅថ្ងៃទី ៣១ ខែធ្នូ ( មិន-មែនសរសេរបិទ នៅពេលប្រើប្រាស់អស់សន្លឹកនោះទេ ) ។

សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្រោយពីសរសេរបិទឆ្នាំអនុវត្ត ហើយបើសិនជាមាននៅសល់សន្លឹកត្រូវប្រើប្រាស់បន្ត ដោយចាប់ផ្តើមពីលេខ០១ (មួយ) មកវិញ ។ សៀវភៅចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលបានប្រើប្រាស់រួច ត្រូវរក្សាទុកនៅ ៖

- ឃុំ ឬ សង្កាត់ បើប្រើប្រាស់នៅ ឃុំ ឬ សង្កាត់
- ក្រុង ស្រុក ខណ្ឌ បើប្រើប្រាស់នៅ ក្រុង ស្រុក ខណ្ឌ [4]

## ១.៣ ៖ សារប្រយោជន៍នៃអត្រានុកូលដ្ឋាន

អត្រានុកូលដ្ឋាន ជាសេវាមូលដ្ឋានរបស់រដ្ឋដែលផ្តល់ផលប្រយោជន៍ចំពោះប្រជាពលរដ្ឋផង និងចំពោះសង្គមជាតិផង ។ អត្រានុកូលដ្ឋានជាកត្តាមួយចូលរួមចំណែលក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច

[4] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

និងហិរញ្ញវត្ថុ ដើម្បីសង្គមមានភាពសុខសាន្ត និងសុវត្ថិភាពដ៏រឹងមាំ ។ សៀវភៅអត្រានុកូលដ្ឋានបាន តម្កល់ទុកជាសក្ខីកម្មដែលមានប្រយោជន៍សម្រាប់ទិន្នន័យវិភាគនូវឯកសារសុខភាព អប់រំ និងសេវាកម្ម សង្គមគ្រប់ប្រភេទ ដូចជាសម្រាប់ធ្វើបញ្ជីបោះឆ្នោត ទិញលក់ដីធ្លី និងទិញលក់ចលនទ្រព្យ និងអចលន ទ្រព្យ និងសម្រាប់ទារពន្ធដារជាដើម ។

អត្រានុកូលដ្ឋាន បានផ្តល់នូវសារប្រយោជន៍សំខាន់ពីរយ៉ាង ចំពោះសង្គមជាតិ និងចំពោះខ្លួន យើង ។

### ១.៣.១ ៖ ចំពោះសង្គមជាតិ

អត្រានុកូលដ្ឋាន ជួយពង្រឹងនីតិរដ្ឋ និងអភិវឌ្ឍប្រទេសជាតិ មានន័យថាអត្រានុកូលដ្ឋានជា យុទ្ធសាស្ត្ររួមក្នុងការធានានូវការអនុវត្តច្បាប់ ពីព្រោះថា បើប្រជាពលរដ្ឋមានឯកសារអត្រានុកូលដ្ឋាន គ្រាប់ៗគ្នានោះ ការប្រតិបត្តិច្បាប់ និងដំណើរការស្ថាប័ននានា អាចប្រព្រឹត្តទៅដោយរលូន និងមាន ប្រសិទ្ធិភាពខ្ពស់ ។

**ឧទាហរណ៍៖** បើប្រជាពលរដ្ឋបានបំពេញកាតព្វកិច្ចចុះអត្រានុកូលដ្ឋានគ្រប់ៗរូប នោះវានឹង ផ្តល់លទ្ធភាពងាយស្រួលដល់រដ្ឋក្នុងការគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ និង ងាយស្រួលលើកផែនការ អភិវឌ្ឍន៍។

**ឧទាហរណ៍** ៖ បើរដ្ឋឃើញថា តំបន់ណាមួយ ឬ ខេត្តណាមួយមានកំណើនខ្ពស់ រដ្ឋត្រូវត្រៀម សាលារៀន និងគ្រូបង្រៀន។ ផ្ទុយទៅវិញ បើអត្រាមរណភាពខ្ពស់ ត្រូវរកវិធានការដើម្បីទប់ទល់ ដោយ លើកតម្កើងការផ្តល់សេវាសន្តិសុខ និងសុខភាព។

ម្យ៉ាងទៀតក្នុងការលើកស្ទួយសិទ្ធិមនុស្ស ការចុះសៀវភៅអាពាហ៍ពិពាហ៍នាំឲ្យសហព័ទ្ធត្រូវគោ រពសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដូចជាជួយទប់ស្កាត់ប្តី ឬ ប្រពន្ធមិនឲ្យទៅរៀបអាពាហ៍ពិពាហ៍ជាមួយ បុគ្គលផ្សេងទៀតតាមទំនើងចិត្តបាន ។ ក្រៅពីនេះយើងឃើញថាអត្រានុកូលដ្ឋានបានលើកកំពស់ កិត្យានុភាពជាតិ តាមរយៈប្រជាពលរដ្ឋយើងមានសំណុំឯកសារគ្រប់ៗគ្នា មានន័យថាពលរដ្ឋយើងបាន បំពេញកាតព្វកិច្ចរបស់ខ្លួន ហើយតំរូវឲ្យខ្លួនមានករណីកិច្ចក្នុងសង្គម ដែលជាហេតុធ្វើឲ្យសង្គមមានការ អភិវឌ្ឍន៍តាមគោលការណ៍នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ ។ ទាំងនេះហើយជាភាពថ្លៃថ្នូរ និងកត្តិយស របស់ប្រទេសជាតិ ។

ទន្ទឹមនឹងនេះផងដែរអត្រានុកូលដ្ឋាន បានជួយពង្រឹងសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ពីព្រោះ ឯកសារអត្រានុកូលដ្ឋាន បានបង្ហាញប្រាប់នូវអត្តសញ្ញាណនៃរូបវន្តបុគ្គលក្នុងទំនាក់ទំនងគតិ យុត្ត ( សកម្មភាពទាក់ទងនឹងសិទ្ធ និង កាតព្វកិច្ច ) ។ ហេតុនេះហើយឯកសារអត្រានុកូលដ្ឋានមាន ប្រយោជន៍ជាសំណុំលិខិតគតិយុត្តកម្មដែលត្រូវយកមកជាភស្តុតាងក្នុងនីតិវិធីតុលាការ ។

### ១.៣.២ ៖ ចំពោះពលរដ្ឋ

- សម្រាប់បញ្ជាក់ពីស្ថានភាព ឋានៈ និងសិទ្ធិនៅក្នុងរង្វង់គ្រួសារ
- សម្រាប់សុំលិខិតឆ្លងដែន

- សម្រាប់សុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងចេញសៀវភៅគ្រួសារ និង ប័ណ្ណស្នាក់នៅ
- សម្រាប់សុំចូលបំរើការងារផ្សេងៗ ដើម្បីបញ្ជាក់ថាបុគ្គលម្នាក់មានអាយុអាចបំពេញការងារបាន
- សម្រាប់ចុះឈ្មោះចូលរៀនតាមគ្រឹះស្ថានសិក្សានានារបស់ស្ថាប័នរដ្ឋ ឬ ឯកជន ( គ្រាប់អាយុចូលរៀន )
- សម្រាប់ចុះឈ្មោះបោះឆ្នោត និងឈរឈ្មោះបោះឆ្នោត
- សម្រាប់ការពារនូវសិទ្ធិរបស់បុគ្គលម្នាក់ៗ ជាពិសេសស្ត្រី និងកុមារ
- សម្រាប់ពេលសវនាការ ឬពេលដោះស្រាយវិវាទ

## ១.៤ ៖ បំរាម និង ការទទួលខុសត្រូវចំពោះមុខច្បាប់អំពីការងារអត្រានុកូលដ្ឋាន

### ១.៤.១ ៖ បំរាម

មន្ត្រីអត្រានុកូលដ្ឋាន ដែលបានអនុវត្តការងារទាក់ទងនឹងអត្រានុកូលដ្ឋាននៅក្នុងឃុំ ឬ សង្កាត់របស់ខ្លួនត្រូវជៀសវាងនូវអំពើមិនគប្បីមួយចំនួនដូចខាងក្រោម ៖

- រាល់សំបុត្រអត្រានុកូលដ្ឋានថតចម្លង ( ហ្វូតូកូពី ) មិនមានតម្លៃប្រើប្រាស់ជាផ្លូវការទេ ទោះបីជាមានការបញ្ជាក់នីត្យានុកូលភាពក៏ដោយ ។ មន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរក្រុង ស្រុក ខណ្ឌ រាជធានីខេត្ត មិនត្រូវបញ្ជាក់លើសំបុត្រអត្រានុកូលដ្ឋានថតចម្លង ( ហ្វូតូកូពី ) នោះទេ ។
- ហាមយកសំបុត្រអត្រានុកូលដ្ឋាន របស់ជនណាម្នាក់ ទៅប្រើប្រាស់ធ្វើជាសំបុត្រអត្រានុកូលដ្ឋានផ្ទាល់ខ្លួនរបស់ជនណាម្នាក់ផ្សេងទៀត ពីព្រោះសំបុត្រអត្រានុកូលដ្ឋានរបស់ជនណាមួយជាកម្មសិទ្ធិសម្រាប់តែជននោះប៉ុណ្ណោះ មិនអាចអនុញ្ញាតឲ្យជនដ៏ទៃយកទៅប្រើប្រាស់បានឡើយ ។ មិនត្រូវធ្វើការកែតម្រូវបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ដោយមិនអនុវត្តន៍តាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬ តាមបញ្ញត្តិច្បាប់ ឬ ដោយគ្មានអំណាចសាលក្រមស្ថាពររបស់តុលាការ ។
- មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ខុសពីទិន្នន័យដែលមាននៅក្នុងបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋានដែលបានតម្កល់ទុក ។
- មិនត្រូវធ្វើការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ដោយពុំបានយកសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម មកធ្វើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីនៃសៀវភៅអត្រានុកូល-ដ្ឋានដែលបានតម្កល់ទុក ។
- មិនត្រូវធ្វើការថតចម្លងលើក្រដាសសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានច្បាប់ដើម ដែលក្រសួងមហាផ្ទៃបានផ្តល់ជូនយកទៅថតចម្លងរួចចុះហត្ថលេខាបោះត្រាចម្លងចេញជូនប្រជាពលរដ្ឋប្រើប្រាស់ ។
- មិនត្រូវឲ្យបង់ថ្លៃក្រដាស និង តែមប្រ៍លើសពីការកំណត់

- មិនត្រូវធ្វើការ កោស ឆូត លុប ដោយប្រើទឹកលុប ហើយសរសេរជៀតបន្ថែម ឬ កែទិន្នន័យនៅលើបញ្ជីនៃសៀវភៅអត្រានុកូលដ្ឋាន ឬ លើសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ។
- ហាមមនុស្សម្នាក់ចុះសៀវភៅអត្រានុកូលដ្ឋាន ក្នុងប្រភេទនីមួយៗលើសពី ០១ដង និងនៅច្រើនកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ហាមយកអនីតិជន ( អ្នកមានអាយុតិចជាង ១៨ឆ្នាំធ្វើជាសាក្សី ) ។
- អនីតិជនមិនត្រូវបានអនុញ្ញាតឲ្យផ្តិតមេដៃលើបញ្ជីអត្រានុកូលដ្ឋានឡើយ ។
- ហាមមន្ត្រីអត្រានុកូលដ្ឋាន អនុវត្តការសរសេរសៀវភៅអត្រានុកូលដ្ឋាន សំបុត្រអត្រានុកូលដ្ឋាន និងសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានគ្រប់ប្រភេទខុសពីនីតិវិធីដែលបានកំណត់

### ១.៤.២ ៖ ភារទទួលខុសត្រូវ

- សាមីខ្លួន ឬ អ្នករាយការណ៍ ឬ សាក្សីត្រូវសម្តែងនូវភាពស្មោះត្រង់ ចំពោះការបញ្ជាក់អះអាងរបស់ខ្លួនអំពីហេតុការណ៍ដែលកើតមានឡើង ហើយដែលខ្លួនបានដឹងឮ ឬ ឃើញផ្ទាល់នូវចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្តីពីអត្រានុកូលដ្ឋានតាមប្រភេទ
- ជនណារាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋានចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ឬ យកអត្រានុ-កូលដ្ឋានរបស់អ្នកដ៏ទៃទៅប្រើប្រាស់ជារបស់ខ្លួន ឬ រាយការណ៍សុំចុះអត្រានុកូលដ្ឋានលើសពី ០១ដង នៅទីកន្លែងដដែល ឬ ទីកន្លែងផ្សេងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ប្រើប្រាស់អត្រានុកូលដ្ឋានក្លែងត្រូវពិន័យ និង ត្រូវទទួលទោសតាមបញ្ញត្តិច្បាប់
- មន្ត្រីអត្រានុកូលដ្ឋានត្រូវស្មោះត្រង់ក្នុងការធ្វើអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។ បើមន្ត្រីអត្រា-នុកូលដ្ឋានណាម្នាក់ដែលសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឲ្យប្រជាពលរដ្ឋដែលមកសុំ ឬ បានទារប្រាក់លើសច្បាប់កំណត់ពីប្រជាពលរដ្ឋសម្រាប់ការងារអត្រានុកូលដ្ឋាន ត្រូវពិន័យជាប្រាក់ និង ត្រូវទទួលខុសត្រូវតាមបញ្ញត្តិច្បាប់ ។ សំបុត្រអត្រានុកូលដ្ឋានដែលក្លែងបន្លំបានចេញរួចហើយត្រូវប្រមូលមកវិញ និង ប្តឹងទៅតុលាការដើម្បីបដិសេធ និង សុំផ្តន្ទាទោសតាមច្បាប់ ។[5]

[5] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

# ជំពូកទី ២

# ភារកិច្ចរបស់សមត្ថកិច្ចអនុវត្តការងារអត្រានុកូលដ្ឋាន

## ២.១ ៖ ថ្នាក់ក្រសួង

នាយកដ្ឋានរដ្ឋបាលទូទៅនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ ជាសេនាធិការឲ្យក្រសួងលើការងារស្ថិតិ និងអត្រានុកូលដ្ឋាន និងមានភារកិច្ចដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំពាក់ព័ន្ធការងារអត្រានុ-កូលដ្ឋាន ។
- ណែនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទ។
- ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងប្រទេស ។
- បូកសរុបស្ថិតិប្រជាពលរដ្ឋ ដែលបានចុះសៀវភៅអត្រាអនុកូលដ្ឋានគ្រប់ប្រភេទនៅគ្រប់រាជធានី ខេត្ត ទូទាំងប្រទេស រួចហើយរាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ។
- លើកផែនការស្នើសុំបោះពុម្ពសៀវភៅ និងក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ សម្រាប់ផ្តល់ជូនដល់រាជធានី ខេត្តឲ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលា ។
- រៀបចំការបណ្តុះបណ្តាលការកសាងសមត្ថភាព និង ការអប់រំសាធារណជនអំពីការងារអត្រានុ-កូលដ្ឋាន ។
- រៀបចំអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន ។
- បញ្ចូលទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រព័ន្ធព័ត៌មានវិទ្យា ។
- អនុវត្តការងារចាំបាច់ផ្សេងៗទៀតដែលទាក់ទងនឹងការងារស្ថិតិ និងអត្រានុកូលដ្ឋាន។

**បញ្ជាក់** ៖ ករណីពុំមានសៀវភៅ និងក្រដាសអត្រានុកូលដ្ឋាន ក្រសួងត្រូវឆ្លើយតបជាលាយល័ក្ខអក្សរទៅ រាជធានី ខេត្តវិញនៅក្នុងអំឡុងពេល ១០ថ្ងៃការងារបន្ទាប់ពីទទួលបានសំណើរសុំរបស់រាជធានី ខេត្ត ។[6]

## ២.២ ថ្នាក់រាជធានី ខេត្ត

អភិបាលរាជធានី ខេត្ត ទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាន នៅរាជធានី ខេត្តរបស់ខ្លួន ដោយមានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាននៃទីចាត់ការរដ្ឋបាលសាលារាជធានី ខេត្ត ជាសេនាធិការ និងមានភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងរាជធានី ខេត្ត និងផ្ញើរបាយការណ៍មកក្រសួងមហាផ្ទៃ តាមការកំណត់
- ត្រួតពិនិត្យការអនុវត្តការចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទនៅតាមក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់

[6] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

- បូកសរុបស្ថិតិប្រជាពលរដ្ឋ ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទប្រចាំខែ និងផ្ញើរបាយការណ៍ទៅក្រសួងមហាផ្ទៃ ( នាយកដ្ឋានរដ្ឋបាលទូទៅនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន-ក្រសួងមហាផ្ទៃ ) រៀងរាល់ថ្ងៃទី១៥ នៃខែបន្ទាប់នីមួយៗ
- លើកគម្រោងទៅក្រសួងមហាផ្ទៃ ដើម្បីស្នើសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់ផ្តល់ឲ្យក្រុង ស្រុក ខណ្ឌ ធ្វើការបែងចែកដល់ឃុំ សង្កាត់ និងធ្វើរបាយការណ៍បូកសរុបការប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានឲ្យទាន់ពេលកំណត់
- សហការរៀបចំបណ្តុះបណ្តាល ការងារកសាងសមត្ថភាព និង ការអប់រំសោធារណជនអំពីការងារអត្រានុកូលដ្ឋាន
- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្តីណែនាំ ផែនការណែនាំអំពីអត្រានុកូលដ្ឋានដល់ក្រុង ស្រុក ខណ្ឌ និងឃុំ ឬ សង្កាត់ចំណុះ
- ធ្វើការវាយតម្លៃការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្នុងរាជធានីខេត្តរបស់ខ្លួន
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន

**បញ្ជាក់** ៖ នៅពេលជិតអស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន រាជធានី ខេត្តត្រូវធ្វើសំណើរសុំទៅក្រសួងមហាផ្ទៃ ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូល-ដ្ឋាន ក្នុងករណីពុំទាន់មានសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន រាជធានី ខេត្តត្រូវឆ្លើយតបជាលាយល័ក្ខណ៍អក្សរទៅក្រុង ស្រុក ខណ្ឌវិញនៅក្នុងអំឡុងពេល ១០ថ្ងៃការងារ បន្ទាប់ពីទទួលបានសំណើរសុំរបស់ក្រុង ស្រុក ខណ្ឌ ។[7]

## ២.៣ ថ្នាក់ក្រុង ស្រុក ខណ្ឌ

អភិបាលក្រុង ស្រុក ខណ្ឌទទួលខុសត្រូវក្នុងការត្រួតពិនិត្យ និង អនុវត្តការងារស្ថិតិ និងអត្រានុ-កូលដ្ឋានក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាក្រុង ស្រុក ខណ្ឌ ជាសេនាធិការមានភារកិច្ចដូចខាងក្រោម ៖

- ត្រួតពិនិត្យ និង បូកសរុបស្ថិតិប្រជាពលរដ្ឋទូទាំងក្រុង ស្រុក ខណ្ឌ និងផ្ញើររបាយការណ៍មករាជ-ធានី ខេត្តតាមការកំណត់
- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋាន គ្រប់ប្រភេទប្រចាំខែនីមួយៗតាមឃុំ ឬ សង្កាត់ចំណុះ និងផ្ញើរទៅការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន នៃទីចាត់ការរដ្ឋបាលសាលារាជធានីខេត្ត រៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់នីមួយៗ
- លើកគម្រោងទៅសាលារាជធានី ខេត្ត ដើម្បីស្នើសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទសម្រាប់ធ្វើការបែងចែកដល់ឃុំ ឬ សង្កាត់ និងធ្វើរបាយការណ៍បូកសរុបការប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានឲ្យទាន់ពេលកំណត់

[7] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

- មុននឹងបញ្ជូនសៀវភៅអត្រានុកូលដ្ឋានទៅឲ្យឃុំ ឬ សង្កាត់យកទៅប្រើប្រាស់ ត្រូវបំពេញសន្លឹកដើមដំបូងបំផុត និង ចុះលេខរៀងនៃសៀវភៅអត្រានុកូលដ្ឋាន បន្ទាប់មកដាក់ជូនទៅអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីចុះហត្ថលេខា និង បោះត្រា
- ត្រួតពិនិត្យជាប្រចាំ ការអនុវត្តចុះសៀវភៅអត្រានុកូដ្ឋានគ្រប់ប្រភេទនៅតាមឃុំ ឬ សង្កាត់
- ពិនិត្យរាល់បញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលឃុំ ឬ សង្កាត់ផ្ញើមកក្រុង ស្រុក ខណ្ឌ ពេលដាច់ឆ្នាំនីមួយៗឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងមហាផ្ទៃ
- រក្សាទុកសៀវភៅអត្រានុកូលដ្ឋានឲ្យបានគត់មត់នៅសាលាក្រុង ស្រុក ខណ្ឌមួយច្បាប់ តាមប្រភេទនីមួយៗ និងមួយច្បាប់ទៀតដូចគ្នាផ្ញើរទៅរក្សាទុកនៅសាលារាជធានី ខេត្តសាមី
- ចេញសេចក្ដីចម្លង ឬ សម្រង់នៃអត្រានុកូលដ្ឋានគ្រប់ប្រភេទ ជូនដល់ប្រជាពលរដ្ឋដែលបានមកសុំចម្លងនៅឆ្នាំដែលកន្លងផុត ( ឆ្នាំដាច់ទៅ )
- ផ្សព្វផ្សាយលិខិតបទដ្ឋាន សេចក្ដីណែនាំ ផែនការណែនាំអំពីអត្រានុកូលដ្ឋានដល់ឃុំ ឬ សង្កាត់ចំណុះ
- ធ្វើការវាយតម្លៃការអនុវត្តការងារស្ថិតិ និង អត្រានុកូលដ្ឋានក្រុង ស្រុក ខណ្ឌរបស់ខ្លួន
- ត្រូវធ្វើសំណើរសុំទៅអភិបាលរាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន នៅពេលជិតអស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន
- អនុវត្តការងារចាំបាច់ផ្សេងៗទៀត ដែលទាក់ទងនឹងការងារស្ថិតិ និង អត្រានុកូលដ្ឋាន

**បញ្ជាក់** ៖ នៅពេលជិតអស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើសំណើរសុំទៅរាជធានី ខេត្ត ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន ។ ក្នុងករណីពុំទាន់មានសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋាន រាជធានីខេត្តត្រូវឆ្លើយតបជាលាយល័ក្ខណ៍អក្សរទៅក្រុង ស្រុក ខណ្ឌវិញនៅក្នុងអំឡុងពេល ១០ថ្ងៃការងារ បន្ទាប់ពីទទួលបានសំណើរសុំរបស់ក្រុង ស្រុក ខណ្ឌ ។[៩]

## ២.៤ ថ្នាក់ឃុំ ឬ សង្កាត់

ក្រុមប្រឹក្សាឃុំ ឬ សង្កាត់ទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងដែនដីឃុំ ឬ សង្កាត់ដែលខ្លួនគ្រប់គ្រង មេឃុំ ឬ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋាន និងមានភារកិច្ចដូចខាងក្រោម ៖

- លើកគម្រោងស្នើសុំសៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានមកសាលាក្រុង ស្រុក ខណ្ឌសម្រាប់ប្រើប្រាស់នៅក្នុងឃុំ ឬ សង្កាត់របស់ខ្លួន
- ចលនាប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ ឬ សង្កាត់របស់ខ្លួនឲ្យមកចុះសៀវភៅអត្រានុកូលដ្ឋានឲ្យបានគ្រប់ៗគ្នា និងទាន់ពេលវេលា
- ទទួលពិនិត្យ និង កត់ត្រារឿងហេតុសំខាន់ៗទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និងមរណភាពនៃជនទាំងឡាយ ចុះនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន

[៩] ជំពូកទី ១ ទិដ្ឋភាពទូទៅនៃអត្រានុកូលដ្ឋាន ( កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

- ចេញសេចក្ដីចម្លង ឬ សម្រង់នៃអត្រានុកូលដ្ឋាន ទៅតាមការស្នើសុំរបស់ប្រជាពលរដ្ឋ នៅឆ្នាំដែលមិនទាន់ដាច់
- អនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ និង ធ្វើបុណ្យសព ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋានដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និង បោះត្រាលើបញ្ជី និង សំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬ បដិសេធសំបុត្រអត្រានុកូលដ្ឋានតាមអំណាចសាលក្រមរបស់តុលាការ ឬ បទបញ្ញត្តិនៃច្បាប់
- រក្សាទុកសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទឲ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងគ្រប់គ្រង
- បិទសៀវភៅអត្រានុកូលដ្ឋាន នៅពេលប្រើប្រាស់អស់បញ្ជី និងនៅដាច់ឆ្នាំនីមួយៗក្រោយពីបានពិនិត្យត្រឹមត្រូវរួចរាល់អស់ហើយ
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានដែលបានបិទបញ្ជីរួចទៅសាលាក្រុង ស្រុក ខណ្ឌ នៅដើមខែមករានៃឆ្នាំបន្ទាប់ ដើម្បីយកទៅតម្កល់ទុកនៅសាលាក្រុង ស្រុក ខណ្ឌផ្ទាល់មួយច្បាប់ និងសា-លារាជធានី ខេត្តសាមីមួយច្បាប់
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬ សង្កាត់ ឲ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួនចំពោះការ-ងារអត្រានុកូលដ្ឋាន និង បង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋដែលមកទាក់ទងពីការងារអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋរស់នៅក្នុងឃុំ សង្កាត់ ជារៀងរាល់ខែនាថ្ងៃទី ០៥នៃខែបន្ទាប់ និងរាល់បំណាច់ឆ្នាំនីមួយៗផ្ញើរទៅសាលាក្រុង ស្រុក ខណ្ឌសាមី
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋានអំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់

**បញ្ជាក់** ៖ មន្ត្រីអត្រានុកូលដ្ឋាន មានសិទ្ធិមិនចុះអត្រានុកូលដ្ឋានឲ្យជនណាមួយដែលខ្លួនយល់ឃើញថា ជននោះមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង មិនមែនជាពលរដ្ឋខ្មែរ ។ នៅពេលជិតអស់សៀវភៅ និង ក្រដាស់អត្រានុកូលដ្ឋាន ឃុំ សង្កាត់ ត្រូវធ្វើសំណើរទៅអភិបាលក្រុង ស្រុក ខណ្ឌ ដោយភ្ជាប់ជាមួយនូវរបាយការណ៍ប្រើប្រាស់សៀវភៅ និង ក្រដាស់អត្រានុកូលដ្ឋាន។

## ២.៥ ថ្នាក់ភូមិ

ភូមិទទួលខុសត្រូវអំពីការងារអត្រានុកូលដ្ឋានក្នុងភូមិដែលខ្លួនគ្រប់គ្រង និង មានភារកិច្ចដូចខាងក្រោម ៖

- មេភូមិត្រូវធ្វើចលនាឲ្យប្រជាពលរដ្ឋ ទៅចុះអត្រានុកូលដ្ឋានកំណើត និង មរណភាពឲ្យទាន់ពេលវេលា និងចលនាអ្នកដែលបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីរួចហើយ តែមិនទាន់បានចុះបញ្ជីអាពាហ៍ពិពាហ៍ដើម្បីឲ្យស្របទៅតាមច្បាប់ ត្រូវទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ នៅសាលាឃុំ ឬ សង្កាត់ខាងលំនៅដ្ឋាននារី ស្របតាមក្រមរដ្ឋប្បវេណី និងបទបញ្ញត្តិមួយចំនួនដែលនៅជាធរមាននៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

- មេភូមិត្រូវចេញលិខិតបញ្ជាក់ទទួលស្គាល់កំណើតទារកឲ្យឪពុកម្តាយទារក បើទារកកើតនៅផ្ទះ ដើម្បីឲ្យឪពុកម្តាយទារកមានឯកសារភស្តុតាង សម្រាប់ទៅសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ នៅលំនៅដ្ឋានអចិន្ត្រៃយ៍របស់ខ្លួន ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើតឲ្យកូន
- មេភូមិត្រូវកត់ត្រាប្រចាំខែនីមួយៗ ឲ្យបានច្បាស់លាស់នូវ ទារកដែលទើបកើត ទារកដែលទើបកើតហើយស្លាប់ អ្នកដែលបានមករៀបអាពាហ៍ពិពាហ៍ និងអ្នកដែលរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ និង អ្នកដែលទទួលមរណភាព
- មេភូមិត្រូវស្រង់ស្ថិតិ និង ផ្ញើរស្ថិតិទៅសាលាឃុំ ឬ សង្កាត់ នៅថ្ងៃទី៣០ នៃខែបន្ទាប់ដើម្បីធ្វើការបូកសរុប ។

# ជំពូកទី ៣
# ការចុះបញ្ជីសៀវភៅ និង លិខិតអត្រានុកូលដ្ឋាន

ការចុះបញ្ជីសៀវភៅអត្រានុកូលដ្ឋាន និងសំបុត្រអត្រានុកូលដ្ឋាន គឺជាការផ្តល់នូវឯកសារគតិយុត្តដ៏សំខាន់ចំបាច់ ជូនប្រជាពលរដ្ឋទាក់ទងនឹងកំណើត អាពាហ៍ពិពាហ៍ និង មរណភាព ។ ឯកសារគតិយុត្តទាំងនេះគឺជាឯកសារ និង ភស្តុតាងដ៏មានតម្លៃបំផុតក្នុងជីវិតរបស់មនុស្សម្នាក់ៗសម្រាប់បញ្ជាក់អំពីអត្តសញ្ញាណ និង ស្ថានភាពស៊ីវិលរបស់ខ្លួនក្នុងគោលដៅលើកស្ទួយនូវសិទ្ធិ និង ករណីកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ នៅក្នុងត្រកូលគ្រួសារខ្លួន និង សង្គមជាតិ ។[9]

## ៣.១ ៖ អត្រានុកូលដ្ឋានកំណើត

### ៣.១.១ ៖ សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងកំណើត

**សៀវភៅនិង ក្រដាសអត្រានុកូលដ្ឋានកំណើត រួមមាន ៖**

- សៀវភៅអត្រានុកូលដ្ឋានកំណើត ( សម្រាប់ពលរដ្ឋខ្មែរ )
- សៀវភៅអត្រានុកូលដ្ឋានកំណើត សម្រាប់ជនបរទេស និងជនអន្តោប្រវេសន្តស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត
- សំបុត្រកំណើត
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត ( ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ ឬ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ )
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ( ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ ឬ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ )

### ៣.១.២ ៖ ការចុះសៀវភៅអត្រានុកូលដ្ឋាន និងសំបុត្រអត្រានុកូលដ្ឋានកំណើត

បើមានទារកកើត ឪពុក ឬ ម្តាយមានកាតព្វកិច្ចត្រូវរាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៅសាលាឃុំ ឬ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុកម្តាយទារកនោះមិនឲ្យហួស ៣០ថ្ងៃ ។ ករណីឪពុកម្តាយមានធុរៈចាំបាច់ពុំអាចទៅចុះសៀវភៅអត្រានុកូលដ្ឋានកំណើតបាន អាចពឹងពាក់សាច់ញាតិជានីតិជន ដែលរស់នៅជាមួយឪពុកម្តាយ ឲ្យទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ។ ការដាក់ឈ្មោះគេត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីឪពុកម្តាយទារកនោះ នឹងត្រូវយកសំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍របស់ឪពុកម្តាយទារកនោះ ឬ ឯកសារភស្តុតាងផ្សេងៗ ដែលមានបញ្ជាក់ភាពជាប្តីប្រពន្ធទៅជាមួយផង ( ប្រសិនបើមាន ) ។[10] ទារកដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ក្នុងរយៈពេលកំណត់ ៣០ថ្ងៃ មន្ត្រីអត្រានុកូលដ្ឋាននឹងផ្តល់នូវសំបុត្រកំណើតច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ។

#### ៣.១.២.១ ៖ លិខិតស្នាមនានាដែលទាក់ទងនឹងការចុះអត្រានុកូលដ្ឋានកំណើត

[9] សេចក្តីណែនាំស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានអោយមាននិរន្តភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុកូលដ្ឋានចល័ត

[10] មាត្រា ១៧ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជាឆ្នាំ ២០០០

អ្នកទៅរាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និង សំបុត្រកំណើតត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬលិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតបញ្ជាក់របស់ឪពុកម្ដាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក (ករណីឪពុកម្ដាយទារកពឹងពាក់សាច់ញាតិ ឬ អ្នកជិតខាងឲ្យទៅរាយការណ៍ជំនួស)
- សៀវភៅគ្រួសារដែលមានឈ្មោះឪពុកម្ដាយទារក ( ប្រសិនបើមាន )
- សេចក្ដីចម្លងសំបុត្រកំណើត ឬ សេចក្ដីចម្លងបញ្ជាក់សំបុត្រកំណើតរបស់ឪពុកម្ដាយទារក ( ប្រសិនបើមាន ) ។

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាទុកលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតទារក ក្នុងសំណុំឯក-សារកំណើតនៅឃុំ ឬ សង្កាត់ ៖

- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មន្ទីរពេទ្យ បើទារកកើតនៅមន្ទីរពេទ្យ ឬ
- លិខិតបញ្ជាក់ទទួលស្គាល់កំណើតទារករបស់មេភូមិ បើទារកកើតនៅផ្ទះ ឬ
- កំណត់ហេតុអំពីកំណើតទារករបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ បើទារកកើតនៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ លិខិតបញ្ជាក់ចេញដោយប៉ុស្តិ៍សុខភាពមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ
- លិខិតបញ្ជាក់របស់ឪពុកម្ដាយ អំពីនាមត្រកូល នាមខ្លួន និង ថ្ងៃ ខែ ឆ្នាំកំណើតរបស់ទារក (ករណីឪពុកម្ដាយទារកពឹងពាក់សាច់ញាតិ ឬ អ្នកជិតខាងឲ្យទៅរាយការណ៍ជំនួស)

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវប្រគល់លិខិតស្នាមឲ្យទៅអ្នករាយការណ៍វិញ ក្រៅពីលិខិតស្នាមចាំបាច់ពាក់ព័ន្ធនឹងកំណើតរក្សាទុក ។[11]

### ៣.១.២.២ ៖ ការសរសេរចុះបញ្ជីកំណើត

#### ក. ការចុះបញ្ជីកំណើតសម្រាប់ទារកកើតពីឪពុកម្ដាយជាពលរដ្ឋខ្មែរ

[11] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្ដីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

នៅពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត និង សុំសំបុត្រកំណើត និងបន្ទាប់ពីពិនិត្យឃើញថាត្រឹមត្រូវតាមការកំណត់ចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីបញ្ជាក់កំណើតចំនួន ០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រា-នុកូលដ្ឋានកំណើតភ្លោះ ។

### គ.១ ចំពោះទារកដែលគេបោះបង់ចោល

ប្រសិនបើមានជនណារើសបានទារកដែលគេបោះបង់ចោល ត្រូវយកទៅប្រគល់ឲ្យមន្ត្រី ក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលរើសបានទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវធ្វើកំណត់ហេតុ សៀវភៅអត្រានុកូលដ្ឋានកំណើត ដោយរកឈ្មោះដាក់ឲ្យទារកនោះ ។ ក្នុងករណីចាំបាច់ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រីសុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើត ទារកដែលរើសបាននោះដោយស្មាននិងដាក់ឈ្មោះឪពុកម្តាយថា មិនស្គាល់ ។ ក្នុងករណីដែលគ្មានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹមទេ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូន ទារកដែលរើសបាននោះទៅមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលសង្គ្រោះកុមារកំព្រាដែលនៅជិតបំផុត ដោយភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ទារកនោះ និង ធ្វើកំណត់ហេតុស្តីពីការប្រគល់ទារកជូនមជ្ឈមណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ។[12]

### គ.២ ការសុំកូន

រាល់ការសុំកូនយកទៅចិញ្ចឹម ទាំងការសុំកូនធម្មតា និង ការសុំកូនពេញលេញត្រូវមានសម្រេចពីតុលាការត្រូវយកនាមត្រកូលនៃអ្នកសុំ ហើយត្រូវយកអ្នកសុំនោះធ្វើជាឪពុកម្តាយ ហើយមានសិទ្ធិនិងករណីកិច្ចដូចគ្នានឹងកូនបង្កើត ។ ការសុំទារក ឬ កុមារដែលកំពុងចិញ្ចឹមបីបាច់ថែរក្សាក្នុងមជ្ឈ-មណ្ឌលសង្គ្រោះទារក ឬ មជ្ឈមណ្ឌលកុមារកំព្រា ការសុំទារកដែលរើសបាន និងការសុំទារក ឬ កូនដែលកំពុងចិញ្ចឹមដោយឪពុកម្តាយ មកធ្វើជាកូនចិញ្ចឹមរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តផ្អែកតាមក្រមរដ្ឋប្បវេណី និងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ។

### គ.៣ ទារកដែលកើតចេញពីពិរុទ្ធជន ឬ ទណ្ឌិត

នៅពេលមានពិរុទ្ធជន ឬ ទណ្ឌិតណាម្នាក់បានសម្រាលកូនក្នុង មណ្ឌលអប់រំកែប្រែ ពេលនោះ អ្នកទទួលខុសត្រូវនៃមណ្ឌលអប់រំកែប្រែ ត្រូវធ្វើកំណត់ហេតុអំពីទារកកើតឲ្យបានត្រឹមត្រូវ ។ ចំពោះកន្លែងកំណើតទារកត្រូវសរសេរទីកន្លែងនៃលំនៅរបស់ឪពុក ឬ ម្តាយទារកមុនក្លាយជាទណ្ឌិត ។

---

[12] មាត្រា១៩ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជាឆ្នាំ ២០០០

- បើទារកនោះមានឪពុកត្រឹមត្រូវនៅរស់ អ្នកទទួលខុសត្រូវនៃពន្ធនាគារត្រូវប្រគល់កំណត់ហេតុនោះឲ្យឪពុកទារកទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួនកំពុងរស់នៅជាប់លាប់ឲ្យទាន់ក្នុងអំឡុងពេល ៣០ថ្ងៃបន្ទាប់ពីទារកនោះកើត ។
- ក្នុងករណីទារកពុំមានឪពុកច្បាស់លាស់ អ្នកទទួលខុសត្រូវនៃពន្ធនាគារ ត្រូវបញ្ជូនកំណត់ហេតុទារកកើត ប្រគល់ឲ្យមន្ត្រីអត្រានុកូលដ្ឋានដែលម្តាយទារកនោះរស់នៅជាប់លាប់ មុនពេលក្លាយទៅជាទណ្ឌិតដើម្បីចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ។

### ក.៤ កូនដែលកើតចេញពីឪពុកម្តាយគ្មានចំណងគតិយុត្ត

ទារកដែលកើតចេញពីឪពុកម្តាយ គ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ក៏ត្រូវចុះសៀវភៅអត្រានុកូលដ្ឋានកំណើតដែរ នៅពេលធ្វើសំបុត្រកំណើត ប្រសិនបើឪពុក និងម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះ បានឆ្លើយទទួលស្គាល់ដោយជាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជាកូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុក និងម្តាយនោះ ជាឪពុកម្តាយរបស់កូននោះ ។[13]

- ក្នុងករណីមានតែឪពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូនដែលទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។
- ក្រោយពីឪពុក ឬ ម្តាយបានប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ឪពុក ឬ ម្តាយដែលមិនទាន់ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្តាយអាចប្តឹងសុំទទួលស្គាល់ទារកនោះបានជាក្រោយ ។
- កូនឥតខាន់ស្លាដែលឪពុក ឬ ម្តាយបានទទួលស្គាល់ នឹងទៅជាកូនមានខាន់ស្លាបាន ប្រសិនបើក្រោយពីកំណើតកូននោះ ឪពុក ឬ ម្តាយកូននោះបានសុំចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នា
- ការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះសំបុត្រអាពាហ៍ពិពាហ៍ ឬ ក្រោយចុះសំបុត្រអាពាហ៍ពិពាហ៍ក៏បាន ។[14]

### ខ. ការចុះបញ្ជីកំណើតសម្រាប់ទារករបស់ជនបរទេស និងជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់នៅកម្ពុជា

ជនបរទេស និង ជនអន្តោប្រវេស្តដែលរស់នៅស្របច្បាប់ ហើយបានកើតទារកនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាឪពុកម្តាយទារកនោះ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចទៅសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួននៅប្រចាំព្រះរាជាណាចក្រកម្ពុជា

---

[13] មាត្រា២៣ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជាឆ្នាំ ២០០០

[14] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

ប្រសិនបើមាន ។ ចំពោះជនបរទេស ឬ ជនអន្តោប្រវេស្តស្របច្បាប់ មករាយការណ៍សុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត ត្រូវតែឪពុក និងម្តាយផ្ទាល់ទើបបានគឺមិនអនុញ្ញាតឲ្យអ្នកដទៃមករាយការណ៍ជំនួសឡើយ ។

លិខិតស្នាមនានាដែលឪពុកម្តាយទារក ត្រូវបង្ហាញមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ដើម្បីសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតមាន ៖

- លិខិតស្នើរសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតឆ្លងដែនសាមីខ្លួនរបស់ឪពុក ឬ ម្តាយទារក និង ទិដ្ឋាការដែលនៅមានសុពលភាព ឬ បង្កាន់ដៃ " ប " ( ប១ សម្រាប់គ្រួសារ ប៣ សម្រាប់បុគ្គលម្នាក់ ) អនុញ្ញាតឲ្យស្នាក់នៅកម្ពុជាដែលនៅមានសុពលភាព ( ចំពោះជនបរទេស និង អន្តោប្រវេស្ត )
- សំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ។ ករណីគ្មានសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក្យថា " **គ្មានខាន់ស្លា** " ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងកំណើតទារក ៖

- លិខិតទទួលស្គាល់កំណើតរបស់មន្ទីរពេទ្យដែលជាកន្លែងកើតរបស់ទារក បើទារកកើតនៅមន្ទីរពេទ្យ
- លិខិតឆ្លងដែនសាមីខ្លួនរបស់ឪពុក ឬ ម្តាយទារកនិងទិដ្ឋាការដែលនៅមានសុពលភាព ឬ បង្កាន់ដៃ " ប " ( ប១ សម្រាប់គ្រួសារ ប៣ សម្រាប់បុគ្គលម្នាក់ ) អនុញ្ញាតឲ្យស្នាក់នៅកម្ពុជាដែលនៅមានសុពលភាព ( ចំពោះជនបរទេស និងអន្តោប្រវេស្ត )
- លិខិតស្នើសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើត
- ច្បាប់ថតចម្លងលិខិតស្នាមផ្លូវការផ្សេងៗ ដែលចេញដោយអាជ្ញាធរនៃព្រះរាជាណាចក្រកម្ពុជា ឬ អាជ្ញាធរនៃប្រទេសសាមីរបស់ឪពុក ឬ ម្តាយទារក ( ប្រសិនបើមាន ) ។

មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឲ្យបានច្បាស់លាស់ បើឃើញថាត្រឹមត្រូវតាមការកំណត់ខាងលើហើយ ទើបចាប់ផ្តើមសរសេរចូលបញ្ជីកំណើត ដោយអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីកំណើតសម្រាប់ទារកកើតពីឪពុកម្តាយជាពលរដ្ឋខ្មែរដែរ ។[15]

### ៣.១.២.៣ ៖ ការសរសេរសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក

[15] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

ក្រោយពីសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានកំណើតទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឲ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីកំណើត ហើយបោះត្រា និង ចុះហត្ថលេខាលើបញ្ជីទាំងពីរ និង សំបុត្រកំណើតច្បាប់ដើម ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រកំណើតច្បាប់ដើមនេះ ទៅឲ្យអ្នកមករាយការណ៍កំណើតទារក ដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំឲ្យរក្សាទុកឲ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រកំណើតច្បាប់ដើមជូនជាលើកទីពីរបានទេ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រកំណើតច្បាប់ដើមគឺជាឯកសារផ្ទាល់ខ្លួន មានតែមួយច្បាប់ប៉ុណ្ណោះ ។ សំបុត្រកំណើតច្បាប់ដើមមិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ជៀសវាងការបាត់បង់ត្រូវធ្វើសេចក្តីចម្លងសំបុត្រកំណើតអោយហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ។

## ៣.១.៣ ៖ ការចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត

ប្រជាពលរដ្ឋខ្មែរដែលបានកើតហើយទុកឲ្យហួសរយៈពេល ៣០ថ្ងៃ ហើយពុំទាន់មានសំបុត្រកំណើតប្រើប្រាស់ សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលត្រូវប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតនៅសាលាឃុំ ឬ សង្កាត់សាមីដែលខ្លួនរស់នៅពិតប្រាកដ មកបញ្ជាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានកំណើត នៅសាលាឃុំ ឬ សង្កាត់សាម៉ី ដែលខ្លួនរស់នៅពិតប្រាកដបច្ចុប្បន្ន ដោយនាំទៅជាមួយនូវសាក្សីមានចំនួន ០២រូប ជានីតិជន ហើយត្រូវមានលំនៅដ្ឋានពិតប្រាកដបញ្ជាក់នូវចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។ ពាក្យប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតរបស់សាមីខ្លួន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលចំនួន ០១ច្បាប់ ត្រូវបង់ថ្លៃ ១.០០០រៀល សម្រាប់ប្រជាពលរដ្ឋដែលមានទីលំនៅ នៅក្នុងខេត្តរតនគីរី ឧត្តរមានជ័យ មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និងមានការបង់ ៤.០០០ រៀល សម្រាប់ប្រជាពលរដ្ឋដែលមានលំនៅក្រៅពីខេត្តខាងលើ ។ ចំពោះមន្ត្រីរាជការដែលទទួលបៀវត្ស ឬ ទទួលសោធននិវត្តន៍ ត្រូវយកឯកសារបៀវត្ស ឬសោធននិវត្តន៍ ឬសេចក្តីបញ្ជាក់ពីក្រសួងស្ថាប័នសាមី ដើម្បីសុំសំបុត្របញ្ជាក់កំណើត ហើយថ្ងៃ ខែ ឆ្នាំកំណើត ដែលចុះក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត មិនត្រូវខុសពីថ្ងៃ ខែ ឆ្នាំកំណើត ដែលមាននៅក្នុងឯកសារបៀវត្ស ឬ សោធននិវត្តន៍ជាផ្លូវការឡើយ ។[16]

### ៣.១.៣.១ ៖ លិខិតស្នាមនានាទាក់ទងនឹងការបញ្ជាក់កំណើត

សាមីខ្លួន និង សាក្សីត្រូវភ្ជាប់មកជាមួយនូវលិខិតស្នាមចាំបាច់មួយចំនួនដូចខាងក្រោម ៖

- សៀវភៅគ្រួសាររបស់សាមីខ្លួន និង របស់សាក្សី ឬ

[16] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

- អត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និង របស់សាក្សី (ប្រសិនបើមាន) ឬ
- ឯកសារបៀវត្ស ឬ សោធននិវត្តន៍

បើអាចធ្វើបាន មន្ត្រីអត្រានុកូលដ្ឋានត្រូវរក្សាទុកលិខិតស្នាមចាំបាច់ ដែលពាក់ព័ន្ធនឹងការបញ្ជាក់កំណើត ៖

- ច្បាប់ថតចម្លងសៀវភៅគ្រួសាររបស់សាមីខ្លួន និង របស់សាក្សី ឬ
- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណរបស់សាមីខ្លួន និង របស់សាក្សី ឬ
- ច្បាប់ថតចម្លងឯកសារបៀវត្ស ឬ សោធននិវត្តន៍ ឬ សេចក្តីបញ្ជាក់ពីស្ថាប័នសាមី បើជាមន្ត្រីរាជការ ។

#### ៣.១.៣.២ ៖ ការសរសេរចុះបញ្ជីបញ្ជាក់កំណើត

នៅពេលមានអ្នកមករាយការណ៍ សុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និងសំបុត្របញ្ជាក់កំណើត និង បន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវតាមការកំណត់ចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចុះបញ្ជីបញ្ជាក់កំណើតចំនួន ០២ច្បាប់មានខ្លឹមសារដូចគ្នាទាំងស្រុង នៅក្នុងសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើតភ្លោះ ។ របៀបការសរសេរចុះបញ្ជីបញ្ជាក់កំណើត នៃសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីកំណើតដែរ ។[17]

#### ៣.១.៣.៣ ៖ ការសរសេរសំបុត្របញ្ជាក់កំណើតច្បាប់ដើមមួយសន្លឹក

ក្រោយពីសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានកំណើតទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រកំណើតច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឲ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីកំណើត ហើយបោះត្រា និង ចុះហត្ថលេខាលើបញ្ជីទាំងពីរ និងសំបុត្រកំណើតច្បាប់ដើម រួចមន្ត្រីអត្រានុកូលដ្ឋានប្រគល់ឲ្យទៅសាមីខ្លួន ដែលមកសុំចុះសៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត និង ណែនាំឲ្យអ្នកនោះថែរក្សាទុកដាក់ឲ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្របញ្ជាក់កំណើតច្បាប់ដើម ជូនជាលើកទីពីរបានទេ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបអ្នកមករាយការណ៍ថា សំបុត្រកំណើតច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួន មានតែមួយច្បាប់ប៉ុណ្ណោះ សំបុត្រកំណើតច្បាប់ដើមមិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ជៀសវាងការបាត់បង់ត្រូវធ្វើសេចក្តីចម្លងសំបុត្រកំណើតអោយហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ។

### ៣.១.៤ ៖ សេចក្តីចម្លង ឬ សម្រង់សំបុត្រកំណើត និង សំបុត្របញ្ជាក់កំណើត

ការសុំចម្លង ឬ សម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សម្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ដែលចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ

[17] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

សង្កាត់ ហើយត្រូវបោះត្រាផង ។ ការសុំចម្លង ឬ សម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតក្នុងឆ្នាំកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ។ ការសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាអត្រានុកូលដ្ឋាន និង ត្រូវបានបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬ អភិបាលរងក្រុង ស្រុក ខណ្ឌ ដែលអភិបាលក្រុង ស្រុក ខណ្ឌប្រតិភូកម្ម និងបោះត្រា ។

ចំពោះប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានកំណើត នៅស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។ ការសុំចម្លង ឬ សម្រង់សំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតក្នុងឆ្នាំមិនទាន់ដាច់ អ្នកសុំត្រូវសុំចម្លង ឬ សុំសម្រង់នៅស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ។ ការសុំចម្លង ឬ សម្រង់សំបុត្រកំណើត និង សំបុត្របញ្ជាក់កំណើតក្នុងឆ្នាំកន្លងផុតទៅ អ្នកសុំត្រូវដាក់ពាក្យសុំចម្លង ឬ សុំសម្រង់នៅស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ហើយស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ត្រូវផ្ញើពាក្យសុំចម្លង ឬ សុំសម្រង់មកក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់នៅទី នោះ ។

### ៣.១.៤ .១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងបញ្ជាក់កំណើត

មន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ច្បាប់ដើមដែលសាមីខ្លួនយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតនោះ ពិតជាត្រឹមត្រូវដែលចេញដោយក្រសួងមហាផ្ទៃដែរឬទេ?
- ផ្ទៀងផ្ទាត់សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូល-ដ្ឋាន ឬ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់កំណើត នូវឆ្នាំដែលអនុវត្តសៀវភៅអត្រានុកូលដ្ឋាន លេខសៀវភៅ និងលេខបញ្ជីអត្រានុកូលដ្ឋាន

នៅពេលពិនិត្យសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត ឃើញថាជាសំបុត្រដើមពិតប្រាកដ ហើយទើបមន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និងសំបុត្របញ្ជាក់កំណើតបាន ។[18]

### ៣.១.៤ .២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រកំណើត និង បញ្ជាក់កំណើត

[18] ជំពូកទី ២ អត្រានុកូលដ្ឋានកំណើត (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

នៅពេលសរសេរចូលសៀវភៅចម្លងសំបុត្រកំណើត និង សៀវភៅចម្លងសំបុត្របញ្ជាក់កំណើតចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានត្រូវសរសេរសេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ។ របៀបសរសេរសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត អនុវត្តដូចគ្នានឹងការសរសេរសំបុត្រកំណើត និងបញ្ជាក់កំណើតច្បាប់ដើម ។

## ៣.២ ៖ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍

### ៣.២.១ ៖ សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍

សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងអាពាហ៍ពិពាហ៍ រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍
- សៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍សម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ ( បានអនុវត្តអំឡុងឆ្នាំ ២០០២-២០០៧ )
- សំបុត្រអាពាហ៍ពិពាហ៍
- សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ( បានអនុវត្តអំឡុងឆ្នាំ ២០០២-២០០៧ )
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ( សម្រាប់ចម្លងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ) [19]

### ៣.២.២ ៖ ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ និង មិនប្រកាស

បុរស នារីមានបំណងរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃលំនៅដ្ឋានសាមីខាងនារី ។ ចំពោះបុរស នារីដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ ឬ បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាមប្រពៃណីរួចហើយ ប៉ុន្តែពុំទាន់បានសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីអោយការរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធអោយមានលក្ខណៈជាប្តីប្រពន្ធស្របច្បាប់ ឬ ការរៀបអាពាហ៍ពិពាហ៍មានលក្ខណៈពេញច្បាប់ សាមីខ្លួនទាំងពីររូបត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃលំនៅដ្ឋានរបស់ខ្លួនរស់នៅពិតប្រាកដ ។ បុរស នារីដែលមកសុំច្បាប់រៀបអាពាហ៍ពិពាហ៍ ត្រូវភ្ជាប់មកជាមួយនូវ ៖

- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ។
- លិខិតបញ្ជាក់ភាពនៅលីវ ឬ មេម៉ាយ ឬ ពោះម៉ាយ របស់សាមីខ្លួនទាំង២នាក់ ហើយលិខិតនេះត្រូវចេញដោយមេឃុំ ឬ ចៅសង្កាត់ ។ ក្នុងករណីមេម៉ាយ ឬ ពោះម៉ាយដោយប្តី ឬ ប្រពន្ធស្លាប់

[19] ជំពូកទី ៣ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងសំបុត្រមរណភាព ឬ សេចក្តីចម្លងសំបុត្របញ្ជាក់មរណភាព បើក្នុងករណីមេម៉ាយ ឬ ពោះម៉ាយដោយលែងលះ ត្រូវភ្ជាប់ជាមួយសាលក្រមតុលាការ ។

- សៀវភៅគ្រួសារ ដែលមានទិន្នន័យរបស់សាមីខ្លួនទាំងពីរនាក់ច្បាស់លាស់ និងត្រឹមត្រូវ ។

នៅពេលទទួលបានពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យឲ្យបានហ្មត់ចត់ ចំពោះបុរសនារីដែលបានដាក់ពាក្យសុំនោះ បើពិនិត្យឃើញថា មិនមានលក្ខណៈត្រឹមត្រូវទៅតាមល័ក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និងបទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានទេ មន្ត្រីអត្រានុកូលដ្ឋានមិនអាចអនុញ្ញាតឲ្យបុរសនារីនោះរៀបអាពាហ៍ពិពាហ៍ឡើយ ។ បើពិនិត្យឃើញថា មានលក្ខណៈត្រឹមត្រូវទៅតាមល័ក្ខខណ្ឌនៃក្រមរដ្ឋប្បវេណី និង បទប្បញ្ញត្តិនៃអត្រានុកូលដ្ឋានហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ជាសារធារណៈចំនួន ០៥ច្បាប់ ៖

- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅលំនៅដ្ឋានសាមីខ្លួននារី
- ០១ច្បាប់ បិទផ្សាយជាសាធារណៈ នៅសាលាឃុំ ឬ សង្កាត់សាមីខ្លួននារី
- ០១ច្បាប់ រក្សាទុកជាឯកសារនៅសាលាឃុំ ឬ សង្កាត់សាមីខ្លួននារី
- ០២ច្បាប់ ត្រូវផ្ញើរទៅមន្ត្រីអត្រានុកូលដ្ឋានខាងបុរស ដើម្បីយកទៅបិទផ្សាយជាសារធារណៈ នៅលំនៅដ្ឋានសាមីខ្លួនខាងបុរស០១ច្បាប់ និងនៅសាលាឃុំ ឬ សង្កាត់ខាងបុរស០១ច្បាប់

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ត្រូវបិទផ្សាយជាសាធារណៈក្នុងរយៈពេល១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍តាមប្រពៃណី ឬ ថ្ងៃចុះបញ្ជីអាពាហ៍ពិពាហ៍ ដើម្បីឲ្យជនដែលមានផលប្រយោជន៍ក្នុងរឿងនោះ អាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ។ ផុតរយៈពេល ១០ថ្ងៃអាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងទាស់ បើមានការប្តឹងទាស់អាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែបណ្តឹងទាស់នោះត្រូវបានដោះស្រាយរួចរាល់ទៅតាមគោលការណ៍ដែលបានចែងក្នុងក្រមរដ្ឋប្បវេណី និង បទប្បញ្ញត្តិនៃអត្រានុកូលដ្ឋាន ។[20]អាពាហ៍ពិពាហ៍ ចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាបុរសនិងនារីដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅដ្ឋាននារី ។ កិច្ចសន្យានេះត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និង ផ្តិតមេដៃប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ០២រូប ។[21]

### ៣.២.៣ ៖ ការចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍

#### ៣.២.៣.១ ៖ ការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និង ពលរដ្ឋខ្មែរ

[20] ជំពូកទី ៣ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

[21] មាត្រា ៣០ នៃអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននៅកម្ពុជាឆ្នាំ ២០០០

ក្រោយរយៈពេល១០ថ្ងៃ នៃការបិទផ្សាយជាសាធារណៈ នូវប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និង ប្រសិនបើគ្មានការជំទាស់អំពីអាពាហ៍ពិពាហ៍នេះទេ សាមីខ្លួនទាំង ០២ នាក់អាចសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និង សុំសំបុត្រអាពាហ៍ពិពាហ៍ ដែលចាត់ទុកជាការរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ដោយនាំនូវសាក្សី ០២រូបជានីតិជន ។ ក្នុងករណីដែលអ្នកដែលរស់នៅជាមួយគ្នាជាប្តីប្រពន្ធមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យលិខិតស្នាមឲ្យបានត្រឹមត្រូវទៅតាមការកំណត់ ប្រសិនបើឃើញថាត្រឹមត្រូវហើយនោះ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ០២ ច្បាប់ដែលមានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ ។

### ៣.២.៣.២ ៖ ការចុះបញ្ជីអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ពលរដ្ឋខ្មែរ និង ពលរដ្ឋបរទេស

ត្រូវចាត់ទុកជាជនបរទេស គឺជាជនដែលគ្មានសញ្ជាតិខ្មែរ ទោះបីជាជននោះស្ថិតនៅក្រៅប្រទេសកម្ពុជាក្តី កំពុងស្ថិតនៅ ឬ ស្នាក់នៅក្នុងប្រទេសក្តី ។ ជនបរទេសដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ ។ ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទនៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារជនបរទេស ហើយក្រសួងការបរទេស និងសហប្រតិបត្តិអន្តរជាតិ ត្រូវបញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ដើម្បីពិនិត្យចុះបញ្ជីរួចជូនដំណឹងអំពីការរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនជាពលរដ្ឋខ្មែរ ។[22]

#### ក. សំណុំឯកសារជនបរទេសមាន

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ៤×៦ ថតចំពីមុខក្នុងរយៈពេល ០៣ខែចុងក្រោយ
- ឯកសារថតចម្លងនៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស និង ទិដ្ឋាការចូលប្រទេសកម្ពុជាដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

[22] ជំពូកទី ៣ អត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ (កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់ពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេស ដែលធានាដល់ជីវភាពរស់នៅចេញដោយសមត្ថកិច្ចនៃប្រទេសសាមីខ្លួនជនបរទេស
- សៀវភៅការងារចំពោះសាមីខ្លួនជនបរទេស ដែលប្រកបមុខរបរធ្វើអាជីវកម្ម ឬ ពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា

**ខ . សុំណុំឯកសារជាពលរដ្ឋខ្មែរមាន**

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍មានបិទរូបថតរបស់សាមីខ្លួនបុរស និងសាមីខ្លួននារី ៤×៦ ថតចំពីមុខក្នុងរយៈពេល ០៣ខែចុងក្រោយ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួន ដែលមានចុះបញ្ជីច្បាស់លាស់ និងត្រឹមត្រូវ
- លិខិតបញ្ជាក់ភាពនៅលីវ ឬ ពោះម៉ាយ ឬ មេម៉ាយចេញដោយមេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋាន អចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដែលមានសុពលភាព ( ករណី ពោះម៉ាយ ឬ មេម៉ាយដោយប្រពន្ធ ឬ ប្តីស្លាប់ ត្រូវមានសំបុត្រមរណភាពរបស់សហព័ទ្ធ បើពោះម៉ាយ ឬ មេម៉ាយដោយការលែងលះ ត្រូវមានសាលក្រមពីតុលាការ )
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការដោយក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- សៀវភៅគ្រួសារដែលមានទិន្នន័យច្បាស់លាស់ និងត្រឹមត្រូវ ។

**៣.២.៣.៣ ៖ ការសរសេរសំបុត្រច្បាប់ដើមមួយសន្លឹក**

ការប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក ក្រោយពីចុះហត្ថលេខា និងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹករួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមនេះ ទៅអោយសាមីខ្លួនប្តីប្រពន្ធ និងណែនាំឲ្យអ្នកនោះថែរក្សាទុកដាក់ឲ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមជូនជាលើកទីពីរបានទេ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបសាមីខ្លួនថា សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួន មានតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះទេ ដូច្នេះគួរតែធ្វើសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ឲ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និង សំបុត្រអាពាហ៍ពិពាហ៍ មន្ត្រី-អត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើត និង សំបុត្របញ្ជាក់កំណើត ។

**៣.២.៤ ៖ សេចក្តីចម្លង ឬសម្រង់សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍**

ការសុំចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ត្រូវសុំចម្លង ឬ សម្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ដែលចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ហើយត្រូវបោះត្រាផង ។ ការសុំចម្លង ឬ សម្រង់អាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ក្នុងឆ្នាំកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ការសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាអត្រានុកូលដ្ឋាន និង ត្រូវបានបញ្ជាក់ហត្ថលេខាដោយអភិបាល ឬ អភិបាលរងក្រុង ស្រុក ខណ្ឌដែលអភិបាលក្រុង ស្រុក ខណ្ឌប្រតិភូកម្ម និងបោះត្រា ។

ចំពោះប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ឬ នៅស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ។ ការសុំចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និង សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ក្នុងឆ្នាំមិនទាន់ដាច់ អ្នកសុំត្រូវសុំចម្លង ឬ សុំសម្រង់នៅស្ថានទូត ឬ ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនោះ ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ហើយត្រូវបញ្ជាក់ហត្ថលេខាដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និងបោះត្រាផង ។ ការសុំចម្លង ឬ សម្រង់សំបុត្រអាពាហ៍ពិពាហ៍ និងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ក្នុងឆ្នាំកន្លងផុតទៅ ត្រូវសុំចម្លង ឬ សម្រង់នៅក្រសួងមហាផ្ទៃដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់តម្កល់នៅទីនោះ ។

#### ៣.២.៤.១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់អាពាហ៍ពិពាហ៍

មន្ត្រីអត្រានុកូលដ្ឋាន និង មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើមដែលសាមីខ្លួនយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍នោះ ពិតជាត្រឹមត្រូវដែលចេញដោយក្រសួងមហាផ្ទៃដែរឬទេ?
- ផ្ទៀងផ្ទាត់សំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ឬ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់អាពាហ៍ពិពាហ៍ នូវឆ្នាំដែលអនុវត្តសៀវភៅអត្រានុកូលដ្ឋានលេខសៀវភៅ និង លេខបញ្ជីអត្រានុកូលដ្ឋាន

នៅពេលពិនិត្យសំបុត្រអាពាហ៍ពិពាហ៍ ឬ សំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ឃើញថាជាសំបុត្រដើមពិតប្រាកដហើយទើបមន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ។

#### ៣.២.៤.២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង បញ្ជាក់អាពាហ៍ពិពាហ៍

នៅពេលសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និង សៀវភៅចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចប់សព្វគ្រប់ហើយ មន្រ្តីអត្រានុកូលដ្ឋាន ឬ មន្រ្តីរក្សាសៀវភៅអត្រានុកូលដ្ឋានត្រូវសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ។ របៀបសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ អនុវត្តដូចគ្នានឹងការសរសេរសំបុត្រអាពាហ៍ពិពាហ៍ និង បញ្ជាក់អាពាហ៍ពិពាហ៍ ច្បាប់ដើម ។

## ៣.៣ ៖ អត្រានុកូលដ្ឋានមរណភាព

### ៣.៣.១ ៖ សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព

សៀវភៅ និង ក្រដាសអត្រានុកូលដ្ឋានទាក់ទងនឹងមរណភាព រួមមាន ៖

- សៀវភៅអត្រានុកូលដ្ឋានមរណភាព ( សម្រាប់ប្រជាពលរដ្ឋខ្មែរ )
- សៀវភៅអត្រានុកូលដ្ឋានមរណភាពសម្រាប់ជនបរទេស និងជនអន្តោប្រវេសន៍ស្របច្បាប់
- សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព ( បានអនុវត្តអំឡុងឆ្នាំ ២០០២-២០០៧ )
- សំបុត្រមរណភាព
- សំបុត្របញ្ជាក់មរណភាព ( បានអនុវត្តអំឡុងឆ្នាំ ២០០២-២០០៧ )
- សេចក្តីចម្លងសំបុត្រមរណភាព ( ក្នុងឆ្នាំសម្រាប់ប្រើប្រាស់នៅឃុំ ឬ សង្កាត់ និងដាច់ឆ្នាំសម្រាប់ប្រើប្រាស់នៅក្រុង ស្រុក ខណ្ឌ )[23]

### ៣.៣.២ ៖ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង សំបុត្រមរណភាព

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ សាច់ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្នុងក្រសួងស្ថាប័នអង្គភាពរបស់អ្នកស្លាប់ត្រូវរាយការណ៍ជូនដល់មន្រ្តីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ឲ្យទាន់រយៈពេល ១៥ ថ្ងៃ ក្រោយពីថ្ងៃទទួលមរណភាព ។ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង ចេញសំបុត្រមរណភាព ត្រូវធ្វើក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ ថ្ងៃចាប់ពីថ្ងៃដែលទទួលមរណភាព ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវផ្តល់សំបុត្ររមណភាពច្បាប់ដើមមួយសន្លឹកដោយឥតគិតថ្លៃ ជូនចំពោះគ្រួសារ ឬ សាច់ញាតិសន្តានដែលមករាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពឲ្យអ្នកស្លាប់ក្នុងរយៈពេលកំណត់ ១៥ ថ្ងៃ ។

បើមានអ្នកស្លាប់ទុកឲ្យហួសរយៈពេល ១៥ ថ្ងៃ នៅក្នុងឆ្នាំនៅពុំទាន់បានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្តឹងសុំសំបុត្រមរណភាពពីមេឃុំ ឬ ចៅសង្កាត់សាមីនៃលំនៅដ្ឋានពិតប្រាកដរបស់អ្នកស្លាប់ ។ ការប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនេះត្រូវបង់ថ្លៃ ១.០០០ រៀល (មួយពាន់រៀល) សម្រាប់ប្រជាពលរដ្ឋដែលមានលំនៅក្នុងខេត្ត

[23] ជំពូកទី ៤ អត្រានុកូលដ្ឋានរមណភាព ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

បន្ទាយមានជ័យ រតនគីរី ព្រះវិហារ មណ្ឌលគីរី ស្ទឹងត្រែង និង ៤.០០០ រៀល (បួនពាន់រៀល) សម្រាប់ប្រជាពលរដ្ឋដែលមានលំនៅក្រៅពីខេត្តខាងលើ ។

បើមានអ្នកស្លាប់ទុកឲ្យហួសឆ្នាំ ហើយពុំទាន់បានទៅរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេក្រុមគ្រួសារនៃអ្នកស្លាប់ត្រូវប្ដឹងសុំសាលក្រមពីសាលាដំបូងរាជធានី ខេត្តសាមីរួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃអ្នកស្លាប់ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន

### ៣.៣.២.១ ៖ លិខិតស្នាមនានាដែលពាក់ព័ន្ធនឹងសព

#### ក. ករណីការចុះអត្រានុកូលដ្ឋានមរណភាព ក្នុងរយៈពេលកំណត់១៥ថ្ងៃ

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ៖

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើអ្នកស្លាប់ដោយរោគ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ផ្សេងមួយទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ករណីអ្នកទោសស្លាប់នៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួងស្ថាប័ន ឬ អង្គភាពបើស្លាប់នៅក្នុង ក្រសួងស្ថាប័ន ឬ អង្គភាព
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)
- សេចក្ដីចម្លងសំបុត្រកំណើត ឬ សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់
សម្រាប់ជនបរទេស និង ជនអន្តោប្រវេសន្ត ត្រូវមានឯកសារបន្ថែមទៀត ៖
- លិខិតឆ្លងដែនរបស់អ្នកស្លាប់ ដែលនៅមានសុពលភាព
- ទិដ្ឋាការ ឬ ប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅមានសុពលភាព
- ក្នុងករណីឯកសារមួយខាងលើនេះបាត់បង់ ត្រូវមានលិខិតនានាដែលបញ្ជាក់ពីអត្តសញ្ញាណទាក់ទងនឹងអ្នកស្លាប់

#### ខ. ករណីការចុះអត្រានុកូលដ្ឋានមរណភាពហួសរយៈពេលកំណត់១៥ថ្ងៃ ក្នុងឆ្នាំមិនទាន់ដាច់

អ្នកទៅរាយការណ៍អំពីមរណភាព ដើម្បីសុំចុះអត្រានុកូលដ្ឋានមរណភាព ត្រូវបង្ហាញចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នូវលិខិតស្នាមមួយចំនួនដូចខាងក្រោម ៖

- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមន្ទីរពេទ្យ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយផ្នែកអនាម័យ បើអ្នកស្លាប់ដោយរោគ ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយសមត្ថកិច្ចជំនាញ ប្រសិនបើករណីស្លាប់ទាក់ទងឃាតកម្ម ឧក្រិដ្ឋកម្ម ឬ
- លិខិតជូនដំណឹងមរណភាពបញ្ជាក់ដោយមេភូមិដែលអ្នកស្លាប់រស់នៅមុនពេលស្លាប់ បើស្លាប់នៅនឹងផ្ទះក្នុងភូមិរបស់សព ឬ
- លិខិតជូនដំណឹងមរណភាពពីមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ផ្សេងមួយទៀត ករណីអ្នកស្លាប់បានស្លាប់នៅក្រៅឃុំ ឬ សង្កាត់ដែលខ្លួនរស់នៅ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវមណ្ឌលអប់រំកែប្រែ ឬ ពន្ធនាគារករណីអ្នកទោសស្លាប់នៅក្នុងមណ្ឌលអប់រំកែប្រែ ឬពន្ធនាគារ ឬ
- លិខិតជូនដំណឹងមរណភាពរបស់អ្នកទទួលខុសត្រូវតាមក្រសួងស្ថាប័ន ឬ អង្គភាពបើស្លាប់នៅក្នុងក្រសួងស្ថាប័ន ឬ អង្គភាព
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ (ប្រសិនបើមាន)
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ (ប្រសិនបើមាន)
- សៀវភៅគ្រួសារ ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកមកប្តឹងសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព

**គ. ករណីការចុះអត្រានុកូលដ្ឋានមរណភាពទុកឲ្យហួសឆ្នាំ**

បើសិនអ្នកស្លាប់ទុកឲ្យហួសឆ្នាំ ហើយពុំបានរាយការណ៍ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពទេ ក្រុមគ្រួសារនៃអ្នកស្លាប់ ត្រូវប្តឹងសុំសាលក្រមពីតុលាការរាជធានី ខេត្តសាមី រួចយកសាលក្រមនោះមកសុំមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃអ្នកស្លាប់ ដើម្បីចុះសៀវភៅអត្រានុកូលដ្ឋាន ។ អ្នកប្តឹងសុំត្រូវមានលិខិតស្នាមមួយចំនួនដូចខាងក្រោម ៖

- សៀវភៅគ្រួសារ ឬសេចក្តីចម្លងសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតរបស់អ្នកប្តឹងសុំ
- សាលក្រមបញ្ជាក់មរណភាពពីតុលាការរាជធានី ខេត្តសាមី
- សៀវភៅគ្រួសារដែលមានឈ្មោះអ្នកស្លាប់នៅក្នុងនោះ ( ប្រសិនបើមាន ) ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់អ្នកស្លាប់ ( ប្រសិនបើមាន ) ឬ
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់អ្នកប្តឹងសុំ ( ប្រសិនបើមាន )

**៣.៣.២.២ ៖ ការអនុញ្ញាតឲ្យធ្វើបុណ្យបូជាសព ឬ បញ្ចុះសព**

ពេលមានអ្នកស្លាប់ភ្លាម ក្រុមគ្រួសារ ឬ ញាតិសន្តាន ឬ អ្នកជិតខាង ឬ អ្នកមានភារកិច្ចនៅក្នុងក្រសួង ស្ថាប័ន អង្គភាពរបស់អ្នកស្លាប់ ត្រូវរាយការណ៍ជូនដល់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់នៃទីកន្លែងរស់នៅជាប់លាប់របស់អ្នកស្លាប់ ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវចេញលិខិតអនុញ្ញាតឲ្យធ្វើបុណ្យ

បូជាសព ឬ បញ្ចុះសពក្នុងករណីអ្នកស្លាប់ដោយជំងឺធម្មតា ដោយចាស់ជរា ដោយគ្រោះធម្មជាតិ ឬ ដោយគ្រោះថ្នាក់ផ្សេងៗ ដែលមិនមានមន្ទិលសង្ស័យទាក់ទងដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋកម្មណាមួយ ។

បើមានអ្នកស្លាប់ ដោយជំងឺឆ្លងរាតត្បាតដែលអាចបណ្តាលឲ្យមានគ្រោះថ្នាក់ដល់សង្គម មន្ត្រីអត្រានុកូលដ្ឋានត្រូវរាយការណ៍ទៅមន្ទីរពេទ្យ ឬ ផ្នែកអនាម័យភ្លាម ។ បើពេទ្យ ឬ ផ្នែកអនាម័យសម្រេចយ៉ាងណា មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុញ្ញាតឲ្យធ្វើការបូជា ឬ បញ្ចុះតាមការសម្រេចនោះ ។

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យពីអំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬ ជនទាំងឡាយដែលបានឃើញ ឬ ដឹងឮហេតុការណ៍នោះត្រូវរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងអ្នកនោះស្លាប់ភ្លាម ដើម្បីឲ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និង ដោះស្រាយរួសរាន់ ។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឲ្យធ្វើបុណ្យបូជា ឬ បញ្ចុះសពបាន ។

បើមានពលរដ្ឋរស់នៅក្នុងឃុំ ឬ សង្កាត់ណាមួយបានទៅស្លាប់នៅឃុំ ឬ សង្កាត់ផ្សេងមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលមានអ្នកស្លាប់ ត្រូវជូនដំណឹងទៅមន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលអ្នកស្លាប់បានរស់នៅមុនពេលស្លាប់ ដើម្បីជូនដំណឹងដល់ក្រុមគ្រួសារនៃអ្នកស្លាប់នោះ ឲ្យទៅយកសពមកធ្វើបុណ្យ និង ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំសង្កាត់ដែលអ្នកស្លាប់នោះបានរស់នៅជាប់លាប់មុនពេលស្លាប់ ។ បើអ្នកស្លាប់គ្មានក្រុមគ្រួសារ ឬ គ្មានអ្នកណាស្គាល់ទេ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ ឬ សង្កាត់ដែលមានអ្នកស្លាប់ត្រូវចាត់ចែងបូជា ឬ បញ្ចុះសពនោះ និង ចុះសៀវភៅមរណភាពនៅក្នុងឃុំ ឬ សង្កាត់នោះ ។

នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព ដើម្បីសុំលិខិតអនុញ្ញាតធ្វើបុណ្យបូជា ឬ បញ្ចុះសព ឬ សុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព និង សំបុត្រមរណភាពមន្ត្រីអត្រានុកូលដ្ឋានត្រូវពិនិត្យមើលលិខិតស្នាមឲ្យបានច្បាស់លាស់ បើឃើញត្រឹមត្រូវតាមការកំណត់ហើយ ត្រូវសរសេរលិខិតអនុញ្ញាតឲ្យធ្វើបុណ្យ ឬ បញ្ចុះសពទៅតាមលក្ខណៈនៃការស្លាប់ ។

### ៣.៣.២.៣ ៖ ការចុះបញ្ជីមរណភាព

នៅពេលមានអ្នកមករាយការណ៍អំពីមរណភាព និង បន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថាត្រឹមត្រូវទៅតាមការកំណត់ចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីមរណភាពចំនួន ០២ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាពភ្លោះ។ នៅពេលសរសេរបំពេញចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឲ្យអ្នករាយការណ៍ពិនិត្យ ក្នុងករណីអ្នកមករាយការណ៍មិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋានត្រូវអានអោយអ្នកមករាយការណ៍ស្តាប់ គ្រប់ចំណុចទាំងអស់ ហើយបើឃើញថាត្រឹមត្រូវ និងឯកភាពហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវ ផ្តិតមេដៃស្តាំ

របស់អ្នកមករាយការណ៍អំពីមរណភាពទុកជាភស្តុតាង បន្ទាប់មកទៀតត្រូវចុះឈ្មោះឃុំ ឬ សង្កាត់ទីកន្លែងដែលចុះសៀវភៅអត្រានុកូលដ្ឋាន ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវចុះហត្ថលេខា និងបោះត្រា ។

ករណីមានពិរុទ្ធជន ឬ ទណ្ឌិតដែលស្លាប់នៅក្នុងពន្ធនាគារ ឬ មណ្ឌលអប់រំកែប្រែអ្នកទទួលខុសត្រូវនៃពន្ធនាគារ និង មណ្ឌលអប់រំកែប្រែនោះ ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយល័ក្ខអក្សរទៅមន្ត្រីអត្រានុកូលដ្ឋាន នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ពិរុទ្ធជន ឬ ទណ្ឌិតនោះដើម្បីមន្ត្រីអត្រានុកូលដ្ឋាន ចុះសៀវភៅអត្រានុកូលដ្ឋានមរណភាព ។ ចំពោះមុខរបរ ត្រូវដាក់មុខរបរមុនពេលជាប់ជាពិរុទ្ធជន ឬ ទណ្ឌិត ទីកន្លែងស្លាប់ត្រូវដាក់ឈ្មោះភូមិ ឃុំ ឬ សង្កាត់ ក្រុង ឬ ស្រុក ឬ ខណ្ឌ រាជធានី ឬ ខេត្ត ប្រទេសដែលពន្ធនាគារ ឬ មណ្ឌលអប់រំកែប្រែតាំងនៅ ។

ចំពោះសាកសពដែលមិនស្គាល់ មន្ត្រីអត្រានុកូលដ្ឋាន ក៏ត្រូវសរសេរចុះក្នុងសៀវភៅអត្រានុកូលដ្ឋានមរណភាព ដែលសរសេរយោងកំណត់ហេតុស្រាវជ្រាវ ហើយសរសេរចុះបញ្ជីតាមខ្លឹមសារនៃកំណត់ហេតុរបស់សមត្ថកិច្ច ដែលមានដូចជា ៖

- ភេទ
- ទីកន្លែងស្លាប់ ( កន្លែងដែលឃើញសាកសព )
- មូលស្លាប់តាមបណ្តឹងរបស់អ្នករាយការណ៍ ( យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច )
- ថ្ងៃ ខែ ឆ្នាំស្លាប់ ( យកតាមកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ច )

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវរក្សាកំណត់ហេតុស្រាវជ្រាវរបស់សមត្ថកិច្ចច្បាប់ចម្លង ០១ច្បាប់ជាឯកសារនៅសាលាឃុំ ឬ សង្កាត់ ។

### ក. សម្រាប់ជនបរទេស និង ជនអន្តោប្រវេសន្តដែលរស់នៅស្របច្បាប់ក្នុងកម្ពុជា

សម្រាប់ជនបរទេស និង ជនអន្តោប្រវេសន្តរស់នៅស្របច្បាប់ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលស្លាប់លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ក្រុមគ្រួសារសាច់ញាតិ ឬ អ្នកទទួលខុសត្រូវ ឬ អាជ្ញាធរមានសមត្ថកិច្ច អាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ ឬ សង្កាត់ដែលអ្នកស្លាប់ធ្លាប់រស់នៅជាប់លាប់មុនពេលស្លាប់ ឬ អាចទៅចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូតស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល នៃប្រទេសរបស់អ្នកស្លាប់ ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើមាន ។ ការចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅឃុំ ឬ សង្កាត់ការចុះឈ្មោះជនជាតិបរទេស ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរខ្មែរផង ហើយរបៀបចុះសៀវភៅអត្រានុកូលដ្ឋានជនបរទេស និង ជនអន្តោប្រវេសន្ត ត្រូវអនុវត្តដូចគ្នានឹងការសរសេរចុះបញ្ជីមរណភាពរបស់ពលរដ្ឋខ្មែរដែរ ។

### ៣.៣.២.៤ ៖ ការសរសេរសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក

ក្រោយពីសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានមរណភាពទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវសរសេរចូលទៅក្នុងសំបុត្រមរណភាពច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឲ្យខុសពីខ្លឹមសារនៅក្នុងបញ្ជីមរណភាពបន្ទប់មកចុះហត្ថលេខា និង បោះត្រាដោយមន្ត្រីអត្រានុកូលដ្ឋានលើបញ្ជីទាំងពីរ និង សំបុត្រច្បាប់ដើម ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រមរណភាពច្បាប់ដើមអោយទៅអ្នកមករាយការណ៍អំពីមរណភាព ដែលសុំចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពដោយមិនបង់ថ្លៃអ្វីឡើយ និងណែនាំអោយរក្សាទុកដាក់អោយបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ព្រោះពុំអាចធ្វើសំបុត្រមរណភាពច្បាប់ដើមជូនជាលើកទីពីរបានទេ ។

## ៣.៣.៣ ៖ សេចក្តីចម្លង ឬ សម្រង់សំបុត្រមរណភាព និង សំបុត្របញ្ជាក់មរណភាព

ការសុំចម្លង ឬ សម្រង់សំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាពក្នុងឆ្នាំមិនទាន់ដាច់ ត្រូវសុំចម្លង ឬ សម្រង់នៅសាលាឃុំ ឬ សាលាសង្កាត់ ដែលចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬ សង្កាត់ ហើយត្រូវបោះត្រាផង ។ ការសុំចម្លង ឬ សម្រង់សំបុត្រមរណភាព និង សំបុត្របញ្ជាក់មរណភាពក្នុងឆ្នាំកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ។ ការសុំចម្លង ឬ សម្រង់នៅសាលាក្រុង ស្រុក ខណ្ឌ ត្រូវចុះហត្ថលេខាដោយមន្ត្រីរក្សាអត្រានុកូលដ្ឋាន និង ត្រូវបានបញ្ជាក់ហត្ថលេខានោះដោយអភិបាល ឬ អភិបាលរងក្រុង ស្រុក ខណ្ឌ ដែលអភិបាលក្រុង ស្រុក ខណ្ឌ ប្រតិភូកម្ម និងបោះត្រា ។

ប្រជាពលរដ្ឋខ្មែររស់នៅស្របច្បាប់ឯបរទេស ដែលបានចុះសៀវភៅអត្រានុកូលដ្ឋានមរណភាពនៅស្ថានទូត ឬ អគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ចំពោះការចម្លង ឬ សម្រង់សំបុត្រមរណភាពនៅមិនទាន់ដាច់ឆ្នាំ ត្រូវសុំចម្លង ឬ ស្រង់នៅស្ថានទូត ឬ អគ្គកុងស៊ុល ឬ ស្ថានកុងស៊ុល ចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាននៅទីនោះ ( ភារធារី ) ហើយត្រូវបញ្ជាក់ហត្ថលេខានោះ ដោយឯកអគ្គរាជទូត អគ្គកុងស៊ុល ឬ កុងស៊ុល និងបោះត្រានៅទីនោះ ។ ចំពោះការការចម្លង ឬសម្រង់សំបុត្រមរណភាព នៅក្នុងឆ្នាំកន្លងផុតទៅ ត្រូវទៅសុំចម្លង ឬ សុំស្រង់នៅក្រសួងមហាផ្ទៃ ដែលមានសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ តម្កល់នៅទីនោះ ។

### ៣.៣.៣.១ ៖ ការសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និង សំបុត្របញ្ជាក់មរណភាព

មន្ត្រីអត្រានុកូលដ្ឋាន និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវពិនិត្យមើលសំបុត្រមរណភាព ឬ សំបុត្របញ្ជាក់មរណភាពច្បាប់ដើម ដែលសាមីខ្លួនយកមក ដោយធ្វើការ ៖

- ពិនិត្យមើលថា តើសន្លឹកនៃសំបុត្រមរណភាព ឬ សំបុត្របញ្ជាក់មរណភាពនោះ ពិតជាត្រឹមត្រូវដែលចេញដោយក្រសួងមហាផ្ទៃដែរឬទេ ?

- ផ្ទៀងផ្ទាត់សំបុត្រមរណភាព ឬ សំបុត្របញ្ជាក់មរណភាព ជាមួយបញ្ជីនៅក្នុងសៀវភៅអត្រានុកូលដ្ឋាន ឬ សៀវភៅអត្រានុកូលដ្ឋានបញ្ជាក់មរណភាព នូវឆ្នាំដែលអនុវត្តសៀវភៅអត្រានុកូលដ្ឋាន លេខសៀវភៅ និងលេខបញ្ជីអត្រានុកូលដ្ឋាន

នៅពេលពិនិត្យសំបុត្រមរណភាព ឬ សំបុត្របញ្ជាក់មរណភាព ឃើញថាជាសំបុត្រដើមពិតប្រាកដហើយទើបមន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន អាចចាប់ផ្តើមសរសេរចូលសៀវភៅចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព ។

### ៣.៣.៣.២ ៖ ការសរសេរសេចក្តីចម្លងសំបុត្រមរណភាព និងសំបុត្របញ្ជាក់មរណភាព

នៅពេលសរសេរចូលសៀវភៅចម្លងសំបុត្រអាពាហ៍ពិពាហ៍ និងសៀវភៅចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ចប់សព្វគ្រប់ហើយមន្ត្រីអត្រានុកូលដ្ឋាន ឬ មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋាន ត្រូវសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ ។ របៀបសរសេរសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬ សេចក្តីចម្លងសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ អនុវត្តដូចគ្នានឹងការសរសេរសំបុត្រអាពាហ៍ពិពាហ៍ និងបញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ។[24]

[24] ជំពូកទី ៤ អត្រានុកូលដ្ឋានរមណភាព ( កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន )

# សេចក្តីសន្និដ្ឋាន

ជាការពិតណាស់ក្រោយពីយើងខ្ញុំបានសិក្សាអស់រយៈពេល ៤ឆ្នាំ និងចុះធ្វើការសាកសួរការងារជាក់ស្តែងនៅក្នុងឃុំ ឬ សង្កាត់ដែលយើងខ្ញុំបានចុះកម្មសិក្សាអស់រយៈពេល ៣សប្តាហ៍កន្លងមកនេះធ្វើឲ្យយើងខ្ញុំអាចសន្និដ្ឋានបានថាៈ ការងារអត្រានុកូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាគឺពិតជាមានសារសំខាន់ណាស់ នៅក្នុងសង្គមនៃព្រះរាជាណាចក្រកម្ពុជាយើងបច្ចុប្បន្ននេះ ពីព្រោះថាបើយើងក្រឡេកមកមើលមនុស្សគ្រប់រូបដែលកើតមកហើយ នៅពេលដែលពេញរូបរាង ក៏ឈានដល់ការរៀបអាពាហ៍ពិពាហ៍ ហើយអ្នកទាំងនោះរមែងតែងតែទទួលមរណភាពទៅវិញ ដោយប្រការណាមួយជាក់ជាមិនខានដោយគ្មាននណាម្នាក់អាចជៀសផុតបានឡើយ ។

មិនតែប៉ុណ្ណោះ បើយើងក្រឡេកមកមើលការរស់នៅក្នុងសង្គមរបស់ប្រជាពលរដ្ឋវិញ យើងឃើញថា អត្រានុកូលដ្ឋានពិតជាបានបង្កលក្ខណៈងាយស្រួលដល់ពួកគាត់ក្នុងការអនុវត្តការងារដែលមានប្រយោជន៍ដល់ខ្លួន ហើយជាពិសេសជាងនេះទៅទៀតនោះ វាក៏ជាការល្អប្រសើរមួយដែលសម្រាប់បំរើផលប្រយោជន៍ដល់សង្គមជាតិក្នុងការអភិវឌ្ឍប្រកបដោយចេរភាព តាមរយៈការគ្រប់គ្រងមួយដែលមានភាពច្បាស់លាស់ ។ ជាងនេះទៅទៀតនោះ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ក៏បានធ្វើឲ្យប្រជាពលរដ្ឋមានការគោរពសិទ្ធិ និង ករណីកិច្ចរបស់ខ្លួនដែលត្រូវធ្វើក្នុងការសុំចុះសំបុត្រអត្រានុកូលដ្ឋានហើយអាចឲ្យមន្ត្រីអត្រានុកូលដ្ឋានបានដឹងថា ការអនុវត្តការងាររបស់ខ្លួនមានភាពងាយស្រួលយ៉ាងម៉េច និង ជួបផលលំបាកយ៉ាងដូចម្តេចខ្លះ ? ហើយត្រូវអនុវត្តយ៉ាងណាដើម្បីបំរើជូនប្រជាពលរដ្ឋ និង សង្គមជាតិរបស់ខ្លួន ។

ប៉ុន្តែ បើទោះបីជាមានអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន ត្រូវបានរៀបចំយ៉ាងល្អយ៉ាងណាក៏ដោយក៏ការអនុវត្តជាក់ស្តែងនៅក្នុងសង្គមខ្មែរយើងបច្ចុប្បន្ន ជៀសមិនផុតពីការខុសឆ្គងផងដែរ ពីព្រោះថាមានមន្ត្រីមួយចំនួននៅតែប្រព្រឹត្តអំពើពុករលួយ ដែលមានការស៊ីសំណូកសូកប៉ាន់ ខ្លះធ្វើការមិនស្មោះត្រង់ មិនអនុវត្តឲ្យបានល្អតាមការណែនាំរបស់អនុក្រឹត្យ ឬ សេចក្តីណែនាំរបស់ក្រសួងពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ដែលជាហេតុធ្វើឲ្យមានផលលំបាកដល់ប្រជាពលរដ្ឋ និង សង្គមបច្ចុប្បន្ន ។

ហើយតាមរយៈសារណានេះ ធ្វើឲ្យយើងខ្ញុំរិតតែយល់កាន់តែច្បាស់ថា ទ្រឹស្តី និង ការអនុវត្តជាក់ស្តែងនៅមានគំលាតនៅឡើយ ។ ជាការឆ្លើយតបទៅនឹងបញ្ហាទាំងអស់ខាងលើនេះ ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រច្បាប់ ខ្ញុំសូមធ្វើការអំពាវនាវ ក៏ដូចជាសំណូមពរដល់គ្រប់បណ្តាក្រសួង ឬស្ថាប័នពាក់ព័ន្ធនានា គាប្បីធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋាននៅទូទាំងប្រទេសឲ្យបានល្អប្រសើរនិង ប្រកបដោយសមត្ថភាព មិនតែបុណ្ណោះ ដើម្បីឲ្យការបំពេញការងារអត្រានុកូលដ្ឋានកាន់តែល្អប្រសើរថែមទៀតនោះ ក្រសួងគួរតែធ្វើការជ្រើសរើសមន្ត្រីអត្រានុកូលដ្ឋានដែលមានកំរិតវប្បធម៌ថ្នាក់បរិញ្ញាបត្រផ្នែករដ្ឋបាល ឬ ផ្នែកនីតិសាស្ត្រដើម្បីឲ្យកាន់តែមានភាពរឹងមាំផ្នែកទ្រឹស្តី និង ការអនុវត្តជាក់ ស្តែង ឲ្យកាន់តែខិតទៅរកចំណុចរួមមួយ ។ ទទឹមនឹងគ្នានេះផងដែរក្រសួង ឬស្ថាប័នពាក់

ព័ន្ធត្រូវតែធ្វើការអនុវត្តច្បាប់ឲ្យមានតម្លាភាព ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើពុករលួយដែលបានអនុវត្តខុសពីគោលការណ៍ច្បាប់ និងការណែនាំរបស់ក្រសួងដែលជាហេតុធ្វើឲ្យមានភាពរញេរញៃ និងច្របូកច្របល់ក្នុងសង្គម ។ ការធ្វើបែបនេះគឺជាគំរូមួយដល់មន្ត្រីអគ្រានុក្កូលដ្ឋានដ៏ទៃទៀត កុំឲ្យយកគំរូតាម ហើយវាក៏ជាផ្នែកមួយក្នុងការចូលរួមចំណែកអភិវឌ្ឍសង្គមឲ្យឈានទៅរកភាពជឿនលឿន និងភាពសម្បូររុងរឿងតាមរយៈការគោរព និងអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព ព្រមទាំងការមិនប្រព្រឹត្តអំពើពុករលួយផងដែរ ។

# អនុសាសន៍

ដើម្បីឲ្យការអនុវត្តការងារអត្រានុកូលដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យកាន់តែមានភាពល្អប្រសើរជាងមុន ក្រសួងនិងស្ថាប័នពាក់ព័ន្ធគួរធ្វើវផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋដើម្បីឲ្យគាន់គាត់បានយល់កាន់តែច្បាស់អំពីតំលៃនិងសារសំខាន់នៃអត្រានុកូលដ្ឋាន ។ ទទឹមនិងគ្នានេះផងដែរ យើងឃើញថា សមត្ថភាពនិងការយល់ដឹងទាក់ទង និង ការងារអត្រានុកូលដ្ឋានរបស់មន្ត្រីអត្រានុកូលដ្ឋានមួយចំនួននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅមានកំរិតនៅឡើយ ដូចនេះក្រសួងគួរតែធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានទាំងនោះឲ្យកាន់តែមានភាពល្អប្រសើរជាងមុនដើម្បីឲ្យគាត់បានដឹងគាត់បានដឹងកាន់តែច្បាស់អំពីតួនាទី និងភារកិច្ចព្រមទាំងការទទួលខុសត្រូវចំពោះមុខច្បាប់ ក៏ដូចជាការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋផងដែរ ។ មិនតែប៉ុណ្ណោះមន្ត្រីអត្រានុ-កូលដ្ឋាន ត្រូវធ្វើការពន្យល់ណែនាំដល់ប្រជាពលរដ្ឋ ឲ្យមកចុះបញ្ជីអត្រានុកូលដ្ឋានឲ្យទាន់ពេលវេលា និង ពន្យល់ដល់ពួកគាត់ឲ្យទុកដាក់ ថែរក្សា សំបុត្រអត្រានុកូលដ្ឋានឲ្យបានល្អជៀសវាងការខូចខាត និងបាត់បង់ដែលបង្ករដល់ការលំបាក ព្រមទាំងមានការខាតបង់ដល់ខ្លួន ។

ក្រៅពីបញ្ហាដែលបានលើកឡើងខាងលើនេះ ក្រសួង និង ស្ថាប័នមានសមត្ថកិច្ចគួរតែមានវិធានការណ៍ និង អនុវត្តច្បាប់ឲ្យកាន់តែមានប្រសិទ្ធិភាព ចំពោះមន្ត្រីណាដែលបានប្រព្រឹត្តអំពើពុករលួយ និងធ្វើការដាក់ពិន័យរាល់ការអនុវត្តការងារអត្រានុកូលដ្ឋានផ្ទុយពីអ្វីដែលច្បាប់បានចែង និង គោលការណ៍របស់ក្រសួងបានដាក់ចុះ ដើម្បីជាគំរូដល់មន្ត្រីដ៏ទៃទៀត ។

# ឯកសារយោង

# ឯកសារយោង

1. អនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋានឆ្នាំ ២០០០
2. អនុក្រឹត្យលេខ ១៧ ស្តីពី " ការកែសម្រួលអនុក្រឹត្យស្តីពីអគ្រានុកូលដ្ឋាន
3. អនុក្រឹត្យលេខ ១០៦ ស្តីពី " ការកែសម្រួលចំណុច (ក) និង ចំណុច (ខ) នៃមាត្រា៥៩ថ្មី នៃអនុក្រឹត្យលេខ ១០៧ ចុះថ្ងៃទី ១៩ មិថុនា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលអនុក្រឹត្យ អគ្រានុកូលដ្ឋាន ចុះថ្ងៃទី២៣ សីហា ឆ្នាំ ២០០៥ "
4. អនុក្រឹត្យលេខ ៤០ស្តីពី " ការកែសម្រួល មាត្រា ៨ និង មាត្រា ៥៩ នៃអនុក្រឹត្យលេខ ១០៣ អនក្របក ចុះថ្ងៃទី ២៩ធ្នូ ឆ្នាំ ២០០០ ស្តីពីអគ្រានុកូលដ្ឋាន"
5. សេចក្តីណែនាំស្តីពី " ការអនុវត្តន៍អនុក្រឹត្យ ស្តីពីការកំណត់បែបបទ និង នីតិវិធីនៃការ រៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និង ពលរដ្ឋបរទេស ឆ្នាំ ២០០៩"
6. សេចក្តីណែនាំលេខ ០០៨ " ស្តីពីការចុះសៀវភៅអគ្រានុកូលដ្ឋានឲ្យមាននិរន្តរភាព ក្រោយពីការបញ្ចប់យុទ្ធនាការ ចុះសៀវភៅអគ្រានុកូលដ្ឋានចល័តឆ្នាំ ២០០៧
7. កំរងឯកសារស្តីពី របៀបកត់ត្រាការងារអគ្រានុកូលដ្ឋាន

# ឧបសម្ព័ន្ធ

**ខេត្ត ~~ក្រុង~~** (១)........... *កណ្ដាល* .............     **លេខ** (៤)............ *២៥* ...............................

**ស្រុក ~~ខណ្ឌ~~** (២)........ *កណ្ដាលស្ទឹង* .........     **សៀវភៅកំណើតលេខ** (៥)....០១/២០១២....

**ឃុំ ~~សង្កាត់~~** (៣)......... *គោកត្រប់* ............     **ឆ្នាំ** (៦)....... *២០១២*....................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | *សម* | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនទារក (៨) | | *សិទ្ធី* | *ប្រុស* | *ខ្មែរ* |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | *SAM* | កូនទី (១២) | មាន ឬឥតខាន់ស្លា (១៣) |
| | នាមខ្លួនទារក | *SITHY* | *មួយ* | *មានខាន់ស្លា* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | | |
| ទីកន្លែងកំណើត (១៥) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ................ | | |

| ឪពុក ម្ដាយទារក | ឪពុក | | ម្ដាយ | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៦) | *សម សោភ័ណ* (១៧) | រស់ ឬ ~~ស្លាប់~~ | *គុណ រតនា* | រស់ ឬ ~~ស្លាប់~~ |
| ជាអក្សរឡាតាំង (១៨) | *SAM SORPHORN* | | *KUN RATANA* | |
| សញ្ជាតិ (១៩) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* | |
| ទីកន្លែងកំណើត (២១) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | .........*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ........................ | | ....... *ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា* ..... | |
| មុខរបរពេលទារកកើត (២២) | *គ្រូបង្រៀន* | | *ជាងកាត់ដេរ* | |
| ទីលំនៅពេលទារកកើត (២៣) | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..... | | ....... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..... | |
| លេខអត្តសញ្ញាណប័ណ្ណ (២៤) | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍ កំណើតទារក (២៥) | *សម សោភ័ណ* | ភេទ (២៦) *ប្រុស* | ឆ្នាំកំណើត (២៧) *១៩៧៥* | សញ្ជាតិ (២៨) *ខ្មែរ* |
| ត្រូវជាអ្វីនឹងទារក (២៩) | *ឪពុកបង្កើត* | | | |
| មុខរបរបច្ចុប្បន្ន (៣០) | *គ្រូបង្រៀន* | | | |
| ទីលំនៅបច្ចុប្បន្ន (៣១) | *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣២) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣៤) ធ្វើនៅ..... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(៣៣) **ស្នាមមេដៃស្ដាំអ្នករាយការណ៍**     (៣៥) **មន្ត្រីអត្រានុកូលដ្ឋាន**

*មេឃុំ*

(៣៦) *ហត្ថលេខា និងត្រា*

*សម សោភ័ណ*     *ទ្រី ហៀង*

**ខេត្ត ក្រុង** (១)........................................ **លេខ** (៤)..................................................
**ស្រុក ខណ្ឌ** (២)..................................... **សៀវភៅកំណើតលេខ** (៥)......................
**ឃុំ សង្កាត់** (៣)..................................... **ឆ្នាំ** (៦)...................................................

# បញ្ជីកំណើតសំរាប់ជនបរទេស និង ជនអន្តោប្រវេសន្តស្របច្បាប់

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | | | ភេទ (៩) |
| នាមខ្លួនទារក (៨) | | | | |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | | កូនទី (១១) | មាន ឬគតខាន់ស្លា (១២) |
| | នាមខ្លួនទារក | | | |
| សញ្ជាតិ (១៣) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | ថ្ងៃ ទី ខែ ឆ្នាំ | | | |
| ទីកន្លែងកំណើត (១៥) | ..........................................<br>.......................................... | | | |

| **ឪពុក ម្តាយទារក** | **ឪពុក** | | **ម្តាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៦) | (១៧) | រស់ ឬស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (១៨) | | | | |
| សញ្ជាតិ (១៩) | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | | | | |
| ទីកន្លែងកំណើត (២១) | ..........................................<br>..........................................<br>.......................................... | | ..........................................<br>..........................................<br>.......................................... | |
| មុខរបរបច្ចុប្បន្ន (២២) | | | | |
| ទីលំនៅបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជា (២៣) | ..........................................<br>..........................................<br>.......................................... | | ..........................................<br>..........................................<br>.......................................... | |
| ទីលំនៅឯបរទេស (២៤) | | | | |
| លិខិតឆ្លងដែនលេខ មានសុពលភាពត្រឹម ថ្ងៃ ខែ ឆ្នាំ (២៥) | | | | |
| ទិដ្ឋាការ ឬលិខិតអនុញ្ញាតអោយស្នាក់នៅកម្ពុជា លេខ ថ្ងៃ ខែ ឆ្នាំ (២៦) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់។

(២៨) ធ្វើនៅ...................... ថ្ងៃទី........... ខែ.................... ឆ្នាំ............

(២៧) **ស្នាមមេដៃស្តាំអ្នករាយការណ៍** (២៩) **មន្ត្រីអត្រានុកូលដ្ឋាន**

(៣០) ហត្ថលេខា និងត្រា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ~~ក្រុង~~** (១) ---- *កណ្ដាល* ------
**ស្រុក ~~ខណ្ឌ~~** (២) ---- *កណ្ដាលស្ទឹង* ---
**ឃុំ ~~សង្កាត់~~** (៣) ---- *គោកត្រប់* -----

**លេខ** (៤)------ *២៥* -------------------
**សៀវភៅកំណើតលេខ** (៥)--០១/២០១២--
**ឆ្នាំ** (៦)-------- *២០១២*-----------------

## សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | *សម* | ភេទ (៩) |
| នាមខ្លួនទារក (៨) | | *សិទ្ធី* | *ប្រុស* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | SAM | |
| | នាមខ្លួនទារក | SITHY | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១២) | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២* | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* ........................................................................ | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | *សម សោភ័ណ* | *គុណ រតនា* |
| ជាអក្សរឡាតាំង (១៥) | SAM SORPHORN | KUN RATANA |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៧) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ...*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា*... | ...*ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*... |
| ទីលំនៅពេលទារកកើត (១៩) | .......*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាល ស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា* | |

(២០) ធ្វើនៅ.... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(២១) **មន្ត្រីអត្រានុកូលដ្ឋាន**
**មេឃុំ**
(២២) *ហត្ថលេខា និងត្រា*
*ទ្រី ហៀង*

~~ខេត្ត~~ ~~ក្រុង~~ (១)....... *រាជធានីភ្នំពេញ*............ **លេខ** (៤)............. *១០*...............................

~~ស្រុក~~ **ខណ្ឌ** (២)...... *សែនសុខ*.................. **សៀវភៅកំណើតលេខ** (៥)... *០១/២០១២* ....

~~ឃុំ~~ **សង្កាត់** (៣)....... *ព្រែកព្នៅ* ............... **ឆ្នាំ** (៦)............ *២០១២*................................

## បញ្ជីបញ្ជាក់កំណើត

| នាមត្រកូល (៧) | | *យឹម* | ភេទ (៩) | សញ្ជាតិ (១០) | កូនទី (១១) |
|---|---|---|---|---|---|
| នាមខ្លួនអ្នកកើត (៨) | | *សុផល* | *ប្រុស* | *ខ្មែរ* | *បី* |
| ជាអក្សរឡាតាំង (១២) | នាមត្រកូល | YIM | | | |
| | នាមខ្លួនអ្នកកើត | SOPHAL | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៣) | | *ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩* | | | |
| ទីកន្លែងកំណើត (១៤) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | ..... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ........................... | | | |

| **ឪពុក ម្ដាយ** | **ឪពុក** | | **ម្ដាយ** | |
|---|---|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៥) | *យឹម ដួង* (១៦) | រស់ ឬស្លាប់ | *នូ ផល្លា* | រស់ ឬស្លាប់ |
| ជាអក្សរឡាតាំង (១៧) | YIM DUONG | | NOU PHALLA | |
| សញ្ជាតិ (១៨) | *ខ្មែរ* | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | *ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ១៩៣៩* | | *ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៤៣* | |
| ទីកន្លែងកំណើត (២០) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ......*ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* ...................... | | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| មុខរបរបច្ចុប្បន្ន (២១) | | | | |
| ទីលំនៅបច្ចុប្បន្ន (២២) | | | | |

| **អំពីសាក្សី** | **សាក្សី** | | **សាក្សី** | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួន (២៣) | *គីម សុខ* (២៤) | ភេទ *ប្រុស* | *នោម វ៉ាឌី* | ភេទ *ស្រី* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | *ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៦១* (២៦) | សញ្ជាតិ *ខ្មែរ* | *ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦៩* | សញ្ជាតិ *ខ្មែរ* |
| ទីកន្លែងកំណើត (២៧) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | .....*ភូមិខ្ពប ឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| មុខរបរបច្ចុប្បន្ន (២៨) | *កសិករ* | | *កសិករ* | |
| ទីលំនៅបច្ចុប្បន្ន (២៩) | ........ *ភូមិដូង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | ........ *ភូមិដូង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| លេខអត្តសញ្ញាណប័ណ្ណ (៣០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣២) ធ្វើនៅ..... *ព្រែកព្នៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(៣១) **ស្នាមមេដៃស្ដាំ** (៣៣) **មន្ត្រីអត្រានុកូលដ្ឋាន**

សាមីខ្លួនសាក្សី សាក្សី **មេឃុំ**

(៣៤) *ហត្ថលេខា និងត្រា*

*យឹម សុផល* *គីម សុខ* *នោម វ៉ាឌី* *ពេជ ណុំ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ---- *រាជធានីភ្នំពេញ* ----  **លេខ** (៤)------ *១០* ------------------

**ស្រុក ខណ្ឌ** (២) ---- *សែនសុខ* -------  **សៀវភៅកំណើតលេខ** (៥)--០១/២០១២--

**ឃុំ សង្កាត់** (៣) ---- *ព្រែកព្នៅ* -----  **ឆ្នាំ** (៦)-------- *២០១២*------------------

# សំបុត្របញ្ជាក់កំណើត

<table>
<tr><td colspan="2">នាមត្រកូល (៧)</td><td>យឹម</td><td>ភេទ (៩)</td></tr>
<tr><td colspan="2">នាមខ្លួនអ្នកកើត (៨)</td><td>សុផល</td><td>ប្រុស</td></tr>
<tr><td rowspan="2">ជាអក្សរឡាតាំង (១០)</td><td>នាមត្រកូល</td><td colspan="2">YIM</td></tr>
<tr><td>នាមខ្លួនអ្នកកើត</td><td colspan="2">SOPHAL</td></tr>
<tr><td colspan="2">សញ្ជាតិ (១១)</td><td colspan="2">ខ្មែរ</td></tr>
<tr><td colspan="2">ថ្ងៃ ខែ ឆ្នាំកំណើត (១២)</td><td colspan="2">ថ្ងៃ សុក្រ ទី ២៥ ខែ សីហា ឆ្នាំ១៩៦៩</td></tr>
<tr><td colspan="2">ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង<br>ប្រទេស</td><td colspan="2">... ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា ....<br>.......................................................................................</td></tr>
</table>

| **ឪពុក ម្ដាយ** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | *យឹម ដួង* | *នូ ផល្លា* |
| ជាអក្សរឡាតាំង (១៥) | *YIM DUONG* | *NOU PHALLA* |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៧) | *ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៣៩* | *ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៤៣* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | *ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* | *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* |

(១៩) ធ្វើនៅ..... *ព្រែកព្នៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២១) *ហត្ថលេខា និងត្រា*

*ពេជ ណុំ*

# សៀវភៅចម្លងសំបុត្រកំណើត និងចម្លងសំបុត្របញ្ជាក់កំណើត (នៅសាលាឃុំ សង្កាត់)

